# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# សុំកូនពេញលេញ

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០២៣ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៣


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **កញ្ញា អៀម លីណា**

**កញ្ញា ឆា៉ា ខុមឡេងអ៊ី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **លោក ញឹក ខុធ្វី**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **អៀម លីណា** និងនាងខ្ញុំឈ្មោះ**ឆាវ៉ា ខុមឡេងអី** ដែលជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៣ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២២-២០២៣ ។

នាងខ្ញុំទាំងពីររូបមានក្តីសោមនស្សយ៉ាងកក់ក្តៅ ដោយមានឱកាសថ្លែងអំណរគុណដល់លោកឪពុក **អៀម រតនា** អ្នកម្តាយ **ម៉ែន លីដា** និង លោកឪពុក **ខុមឆាវ៉ា** អ្នកម្តាយ **ប៉ាន់ គីមហេង** ដែលលោកជាអ្នកមានគុណយ៉ាងលើលលុបបំផុត គ្មានថ្ងៃណាកូនបំភ្លេចបានឡើយ ។

លោកបានផ្តល់កំណើតដល់កូន និងចិញ្ចឹម បីបាច់ថែរក្សាកូនយ៉ាងល្អ ប្រកបដោយ ព្រហ្មវិហារធម៌ ។ លើសពីនេះ លោកបានពុះពារឧបសគ្គគ្រប់បែបយ៉ាងដើម្បីអនាគតកូនដោយ បាន ផ្តល់អោយកូនបានរៀនសូត្រមានចំណេះដឹងរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ។ គ្រប់ដំបូន្មានល្អៗ របស់អ្នកមានគុណកន្លងមកកូនមិនដែលភ្លេចម្តងណាឡើង កូននូវតែចងចាំជានិច្ច និងពិតជាមានតំលៃខ្លាំងណាស់ ។

យើងខ្ញុំទាំងពីរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបង្ហាត់បង្រៀនដល់រូបយើងខ្ញុំ តាំងពី បឋមសិក្សា រហូតដល់បញ្ចប់វិទ្យាល័យ ប្រកបដោយជោគជ័យ ។ ជាពិសេស ក៏សូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ** ដែលជា សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានខិតខំអស់កម្លាំង កាយចិត្តក្នុងការផ្ទេរនូវចំណេះដឹងដល់និស្សិតគ្រប់រូប ពិសេសរូបយើងខ្ញុំរហូតដល់ចប់មហាវិទ្យាល័យនីតិសាស្ត្រនេះ។

នាងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសាស្ត្រាចារ្យជំនួយ លោក **ញឹក ឧត្តី** ដែលលោកមិនត្រឹមតែបានបង្រៀនពួកនាងខ្ញុំកន្លងមកនោះទេ តែលោកថែមទាំងណែនាំសារណាបញ្ចប់ការសិក្សាលើចំណងជើងមួយនេះទៀត ។ លោកបានផ្តល់នូវដំបូន្មានល្អៗ នូវរបៀប ក៏ដូចជាគន្លឹះ ស្វែងរកឯកសារ និងវិធីសាស្ត្រក្នុងការចងក្រងសារណា ។ ជាទីបញ្ចប់នាងខ្ញុំសូមប្រសិទ្ធិពរជូនលោកអ្នកមានគុណទាំអស់ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តរួម ថ្នាក់គ្រប់រូប អោយជួបនូវ ពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជោគជ័យ គ្រប់ភារកិច្ចទាំងអស់ ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្ររយៈពេល៤ឆ្នាំមកនេះនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាសត្តិធ្វើអោយយើងខ្ញុំទទួលបាននូវចំនេះដឹងយ៉ាងច្រើនអនេកពីសំណាក់លោកគ្រូ អ្នកគ្រូដែលបានខំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ហើយក៏ជាសក្ខីភាពដល់រូបយើងខ្ញុំទាំង២នាក់ឈានឆ្ពោះមកដល់ការជ្រើសយកការសរសេរសារណានឹងជ្រើសរើសមុខវិជ្ជាដែលខ្លួនពេញចិត្តហើយយើងខ្ញុំមានទំនោលើប្រធានបទដែលទាក់ទងលើកិច្ចការការពារកុមារនៅក្នុងប្រទេសកម្ពុជាដែលទាក់ទងទៅនឹងប្រធានបទ«ស្មុំកូនពេញលេញ» មកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំទាំង២នាក់ ។

មូលហេតុដែលក្រុមខ្ញុំបានលើកប្រធានបទនេះយកមកសរសេរគឺគោលបំណង  លក្ខខណ្ឌគោលការណ៍សំខាន់ៗនិងនីតិវិធីសម្រាប់ការស្មុំកូនដែលអាចធានាថាមានភាពត្រឹមត្រូវនិយ័តភាពគតិយុត្តិហើយនឹងមានដំណោះស្រាយមួយយ៉ាងពិតប្រាកដចំពោះកុមារដែលជាកូនសុំហើយលើសពីនេះទៅទៀតជាការយកចិត្តទុកដាក់រវាងរដ្ឋនិងរដ្ឋទៅលើទំនាក់ទំនងស្មុំកូនដែលអាចធានាដល់ការការពារសិទ្ធនិងប្រយោជន៍ដល់កុមារគ្រប់រូបដែលកំពុងទាមទារជំនួយពីអ្នករាល់គ្នា។ហើយយើងខ្ញុំទាំងពីរសង្ឃឹមថាសៀវភៅនេះវាជាមូលដ្ឋាននៃការបកស្រាយនិងលើកប្រធានបទនេះមកនិយាយនិងបានចងក្រងជាសៀវភៅគឺសៀវភៅនេះវាគ្រាន់តែជាបកស្រាយនូវបញ្ហាមួយចំនួនទៅតាមលទ្ធភាពដែលពួកខ្ញុំធ្លាប់បានសិក្សាស្រាវជ្រាវនិងតាមឯកសារយោងខ្លះៗនៅក្នុងបណ្ណាល័យ អ៊ីនធឺនេតនិងកន្លែងផ្សេងៗលិខិតបទដ្ឋានគតិយុត្តិផ្សេងៗទៀត។ យើងខ្ញុំសង្ឃឹមថាសៀវភៅនេះវាជាមូលដ្ឋានមួយសម្រាប់ឈានទៅរកភាពលំអិតនិងសម្រាប់បងៗ ប្អូននិស្សិតបានមើលនិងទុកជាឯកសារបំភ្លឺដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗអោយបានយល់ច្បាស់ទាក់ទងនឹងប្រធានបទមួយនេះ។

ជាចុងក្រោយយើងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែរកើតឡើងដោយអចេ្ចតនា នូវពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដោយសារមានការកែនិងផ្ទៀងផ្ទាត់ច្រើនដង នឹងយកចិត្តទុកដាក់ច្រើនប៉ុណ្ណាក៏អាចមានការភ្លាត់ភ្លាំងបន្តិចបន្តួច។ហេតុដូចនេះដើម្បីជួយកែលំអរអោយសៀវភៅនេះកាន់តែល្អ និងមានភាពសុក្រិតនាងខ្ញុំទាំងពីរអ្នកសូមការអធ្យាស្រ័យពីមិត្តអ្នកអានរិះគន់ក្នុងន័យស្ថាបនាដើម្បីអភិវឌ្ឍខ្លួននេងទុកជាបទពិសោធន៍បន្ថែមទៀត។

ជាទីបញ្ចប់យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអានអ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ទទួលបាននូវពរទាំងឡាយបួន សម្បត្តិបី អរីយទ្រព្យប្រាំពីរ និងមានសេក្តីសុខ សំណាងល្អគ្រប់ពេលវេលាជោគជ័យលើការសិក្សា សុខភាពល្អ និងជោគជ័យនូវគោលបំណងដែលបានប៉ងប្រាថ្នាគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** :…………………………………………………………………………………………១

## ជំពូកទី ១

## លក្ខខណ្ឌនៃការបង្កើតស៊ុំកូនពេញលេញ

**ផ្នែកទី១** : **លក្ខខណ្ឌ ចំពោះម្ដាយឪពុកចិញ្ចឹម និង កូនសុំពេញលេញ**…………………….....៥

កថាភាគ ទី១ : អាយុ របស់ឪពុកម្ដាយចិញ្ចឹម…………………………………………………...៥

កថាភាគទី២ : ស្ថានភាពគ្រួសារ………………………………………………………............៦

កថាភាគទី៣ : ជីវភាពរបស់ឪពុកម្ដាយចិញ្ចឹម………………………………………………..៧

កថាភាគទី៤ : អាយុរបស់កូន………………………………………………………………….....៧

កថាភាគទី២ : ស្ថានភាពរបស់កូន…………………………………………………………...…៨

**ផ្នែកទី២** : **លក្ខខណ្ឌ ផ្សេងៗទៀត** ………………………………………………………..…..៨

កថាភាគទី១ : ការយល់ព្រមពីម្ដាយឪពុក បង្កើត……………………………………………..…..៨

កថាភាគទី២ : លទ្ធភាពរបស់ម្ដាយឪពុកបង្កើត……………………………………………...៩

កថាខណ្ឌទី៣ : ផលប្រយោជន៍របស់កូន …………………………………………………....៩

កថាភាគទី៤ : លក្ខខណ្ឌផ្សេងៗមួយចំនួនទៀត ……………………………………………..…១០

**ផ្នែកទី៣** : **ការវិនិច្ឆ័យសេក្ដី និងការចេញដីកាសម្រេច**……………………………………..១២

កថាភាគទី១ : ការពិនិត្យលើភាពចាំបាច់នៃការបង្កើតការស៊ុំកូន……………………………....១២

កថាភាគទី២ : ការចេញសេក្ដីសម្រេច………………………………………………………..១៤

## ជំពូកទី២

## អានុភាព ក្រោយដីកាសម្រេចស៊ុំកូនពេញលេញចូលជាស្ថាពរ

**ផ្នែកទី ១ : អានុភាព លើទំនាក់ទំនងញាតិនិងទ្រព្យសម្បត្តិ**……………………………១៦

កថាភាគទី១ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះកូនសុំ ……………………**១៧**

កថាភាគទី២ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្តាយបង្កើត ………….**១៨**

កថាភាគទី៣ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្តាយចិញ្ចឹម ………....**១៩**

**ផ្នែកទី ២ : ការចុះបញ្ជី អាត្រានុកូលដ្ឋាន** ………………………………………………**២០**

កថាភាគទី១ : ការចុះបញ្ជី និងការកែប្រែអាត្រានុកូលដ្ឋានកំណើតរបស់កូនសុំ …………….....**២០**

កថាភាគទី២ : ការរក្សាការសម្ងាត់អាត្រានុកូលដ្ឋានកំណើតរបស់កូនសុំ………………………**២០**

**ផ្នែកទី៣ : សិទ្ធិដឹងអំពីកំណើតខ្លួន** ……………………………………………………....**២១**

កថាភាគទី១ : ការដាក់ពាក្យសុំទៅតុលាការ……………………………………………….....**២២**

កថាភាគទី២ : ការជួបប្រាស្រ័យជាមួយឪពុកម្តាយបង្កើតនិងបងប្អូនញាតិលោហិត ………......**២៣**

## ជំពូកទី ៣

## ការកាត់កាលកូនសុំពេញលេញ

**ផ្នែកទី១ : មូលហេតុ នៃការកាត់កាល** ……………………………………..……………**២៤**

កថាភាគទី១ : ការបំពានផលប្រយោជន៍…………………………………..…………….**២៥**

កថាភាគទី២ : លទ្ធភាពម្តាយឪពុកបង្កើត…………………………………...………......**២៥**

**ផ្នែកទី ២ : អ្នកមានសិទ្ធប្តឹងកាត់កាល**……………………………………………………...**២៦**

កថាភាគទី១ : តំណាងអយ្យការ…………………………………………..…………..….**២៦**

កថាភាគទី២ : ម្តាយឪពុកបង្កើត………………………………………...……….……...**២៦**

កថាភាគទី៣ : កូនសុំ………………………………………………………...………....**២៦**

**ផ្នែកទី ៣ : អានុភាពនៃការកាត់កាល**…………………………………………………….**២៧**

កថាភាគទី១ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះកូនសុំ ……………...……**២៧**

កថាភាគទី២ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្ដាយបង្កើត ............**២៨**

កថាភាគទី៣ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្ដាយចិញ្ចឹម .............**២៩**

**សេចក្ដីសន្និដ្ឋាន.....................................................................................................៣០**

**អនុសាសន៍ .............................................................................................................៣១**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

មនុស្សគ្រប់រូបនៅលើលោកនេះមិនបុរស ស្ត្រី ក្មេង ចាស់នោះទេតែងតែចង់រស់នៅអោយមានសេចក្ដីស្រលាញ់ភាពកក់ក្ដៅដូចដែលគេហៅថា គ្រួសារ។ ហើយការបង្កើតគ្រួសារគឺផ្ដើមចេញពីសេចក្ដីស្រលាញ់របស់បុរស-នារីដែលមានគោលបំណងរៀបអាពាហ៍ពិពាហ៍ ហើយការរៀបអាពាហ៍ពិពាហ៍គឺជាការបង្កើតកូនសម្រាប់បន្តពូជពង្សវង្សត្រកូលរបស់ខ្លួនដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន និងដើម្បីចិញ្ចឹមបីបាច់ថែរក្សានៅពេលចាស់ជរា។ប៉ុន្តែគ្រប់គ្រួសារទាំងអស់មិនប្រាកដថាអាចសម្រេចចិត្តបានសម្រេចនូវគោលបំណងក្នុងការបង្កើតបន្តវង្សត្រកូលបានទេបញ្ហាភាគច្រើនអាចកើតមកពីកត្តាវេជសាស្ត្រ បញ្ហាសុខភាព តំណពូជខាងស្ត្រីឬបុរសដែលមិនអាចមើលមានកូនបាន។ក្នុងករណីនេះដែលជាហេតុប្ដីប្រពន្ធនៃគ្រួសារមួយមិនអាចបង្កើតកូនដោយខ្លួនឯងបានពួកគេអាចស្វែងរកសុំកូនពីអ្នកដទៃបាន ឬសុំពីសាច់ញាតិទៃបាន ឬសាច់ញាតិខ្លួនឯងបានយកមកចិញ្ចឹមបានគ្រប់គ្រងបីបាច់ថែរក្សាអោយដូចកូនបង្កើតរបស់ខ្លួនដោយផ្ដាច់ទំនាក់ទំនងចេញពីឪពុកម្ដាយបង្កើតរបស់ខ្លួនដែលសកម្មភាពនៃការសុំកូននេះនៅក្នុងច្បាប់ត្រូវបានហៅថា"ការសុំកូន"។នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានបែងចែកអំពីការសុំកូននីមួយៗ គឺមានភាពលំបាកដូចៗគ្នាទៅនឹងនីតិវិធីតុលាការ និងអាជ្ញាធរផងដែរ។

ដើម្បីបង្កើតសុំកូនពេញលេញបានតើមានលក្ខខណ្ឌអ្វីខ្លះ? ហើយ តើនីតិវិធីនៃការសុំកូននេះមានដំណើរការយ៉ាងណាខ្លះ?ចុះនៅពេលដែលការសុំកូនត្រូវបានបង្កើតវិញនោះតើការសុំកូនមានអានុភាពយ៉ាងដូចម្ដេចខ្លះ? ហើយម្យ៉ាងទៀត នៅពេលដែលទំនាក់ទំនងនោះមានការបែកបាក់ដោយហិង្សា ឬ ការមិនមើលថែ តើការកាត់កាលសុំកូនអាចធ្វើនាបដែលរឺទេ?

ការបង្កើតអោយមានការសុំកូននេះគឺដើម្បីអោយមានសន្តតិជននៃទ្រព្យសម្បត្តិរបស់គ្រួសារឪពុកម្ដាយចិញ្ចឹមនឹងមានអ្នកបន្ត នឹងមើលថែគ្រួសាររបស់ឪពុកម្ដាយចិញ្ចឹម។ ហើយការសុំកូននេះដែលមានប្រយោជន៍យ៉ាងខ្លាំងទៅដល់កុមារជាច្រើនដែលត្រូវបានគេបោះបង់ចោលហើយត្រូវបានទទួលអាហារកិច្ចការមើលថែទាំយកទៅចិញ្ចឹមបីបាច់ ។ដើម្បីអោយយល់កាន់តែច្បាស់អំពីការសុំកូនថាតើការសុំកូនជាអ្វី ចែកចេញជាប៉ុន្មានប្រភេទហើយអាចធ្វើឡើងតាមវិធីណាខ្លះហើយមានអានុភាពយ៉ាងដូចម្ដេច និងត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ?

យើងខ្ញុំធ្វើការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទការសុំកូនពេញលេញក្នុងគោលបំណងចង់យល់ដឹងយ៉ាងច្បាស់លាស់ពីការសុំកូនពេញលេញនេះហើយនឹងចង់ចែកចាយចំណេះដឹងនេះបន្តទៅទៀតទៅដល់អ្នកដែលចង់សុំកូនគេយកមកចិញ្ចឹមដើម្បីអោយត្រូវទៅតាមនីតិវិធីច្បាប់។ ហើយសម្រាប់ប្រធានបទនេះយើងខ្ញុំលើកយកតែការសុំកូនពេញលេញមកសិក្សាតែប៉ុណ្ណោះ។

ឆ្លងតាមការសិក្សាស្រាវជ្រាវបកស្រាយប្រធានបទខាងលើនេះរួចមកនាងខ្ញុំយល់ឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមជាតិទាំងមូលហើយបានធ្វើអោយខ្ញុំយល់ដឹងកាន់តែច្បាស់ថាការបង្កើតច្បាប់ទាក់ទងនឹងការសុំកូននេះមកបានជួយការការពារទៅដល់កុមាររងគ្រោះជាច្រើនដែល

កំពុងពិបាកហើយក៏បានជួយទៅដល់គ្រួសារដែលពិបាកនៅក្នុងការមានកូនឬពុំអាចមានកូនបានធ្វើអោយមានគ្រួសារមួយទទួលក្តីសុខនឹង មានសុភមង្គលពេញលេញបរិបូរណ៍ផងដែរ។

មុនពេលដែលមិនទាន់ជ្រើសរើសប្រធានបទនេះមកធ្វើការស្វែងយល់បនកថែមនោះ នាងខ្ញុំគ្រាន់តែយល់ថា ការបង្កើតស្មុំកូនពេញលេញក៏បានធ្វើអោយប្រជាពលរដ្ឋដឹងអំពីការវិនិច្ឆ័យរបស់តុលាការទាក់ទងនឹងស្មុំកូននេះ ថាតើមូលហេតុ ឬស្ថានភាពបែបណាដែលអាចឱ្យឪពុកម្តាយចិញ្ចឹមសុំកូនមកចិញ្ចឹមបាន ។ កាលណាដែលស្មុំបានមក គឺយើងក៏បានដឹងពីអានុភាពនៃស្មុំកូនពេញលេញហើយក៏បានដឹងអំពីការកាត់កាល់និងអានុភាពនៃការកាត់កាល់ផងដែរ ។ ដូច្នេះការដែលបានយល់ដឹងអំពីបញ្ហាទាំងអស់នេះបានគឺមានការជួយបង្រៀនពីលោកគ្រូគួបផ្សំនឹងកិច្ចការស្រាវជ្រាវនេះទើបមានការយល់ដឹងកាន់តែច្បាស់។

ជាមួយគ្នានេះដែរដោយនាងខ្ញុំយល់ឃើញកុមារគឺពិតជាមានសារៈសំខាន់ ជាទំពាំងស្នងឬស្សី ពាក់ព័ន្ធនឹងស្មុំកូននេះរដ្ឋបានចងក្រងច្បាប់ស្តីពី ស្មុំកូនធម្មតា ស្មុំកូនពេញលេញ (ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧) និង ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសដែលចែងពីសិទ្ធិរបស់កូនស្មុំ ពោលគឺបញ្ញត្តិអំពីលទ្ធភាពរបស់អ្នក សុំ ដើម្បីថែរក្សាកូនស្មុំនេះឱ្យបានត្រឹមត្រូវ ។ហើយនៅក្នុងសារណានេះគឺពិតជាមានសារសំខាន់ណាស់សម្រាប់ ការស្មុំកូននៅប្រទេសកម្ពុជាដោយបានពន្យល់បន្ថែមនៅគំនិត នឹងពង្រឹងពីការយល់ដឹងអោយកាន់តែយល់ច្បាស់ទៅលើការទទួលការស្មុំកូនអោយត្រឹមត្រូវទៅតាមច្បាស់គតិយុត្តិ។ការតាក់តែងសារណានេះផងដែរអាចធ្វើឡើងបានទៅដោយរលូនពឹងផ្អែកលើកត្តាធំៗមួយចំនួនដូចជាឯកសាររដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ សារណាបញ្ចប់ការសិក្សាខ្លះរបស់សិស្សច្បង ច្បាប់គោល និងសៀវភៅផ្សេងៗដែលទទួលបានពីបណ្ណាល័យហើយក៏មានការផ្តល់មតិយោបល់ពី សាស្ត្រាចារ្យនិងការអនុវត្តជាក់ស្តែងពីលោកព្រះរាជអាជ្ញា និងចៅក្រមផងដែរ។

នៅក្នុងសារណានេះត្រូវបានបែងចែកជា៣ជំពូកធំៗដូចខាងក្រោម

ជំពូកទី១ លក្ខណ្ឌនៃការបង្កើតស្មុំកូនពេលេញនៅក្នុងជំពូកនេះយើងខ្ញុំធ្វើការបកស្រាយអំពីលក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ចំពោះស្មុំកូនពេញលេញអាយុស្ថានភាគ្រួសារ-កូន ការយល់ព្រមពីឪពុកម្តាយបង្កើត។

ជំពូកទី២ អានុភាពក្រោយដីកាសម្រេចស្មុំកូនពេញលេញចូលជាស្ថាពរយើងខ្ញុំពន្យល់អំពីអានុភាពលើទំនាក់ទំនងលើទ្រព្យសម្បត្តិ ឋានៈបុគ្គការចុះបញ្ជីអាត្រានុកូលដ្ឋាន និងសិទ្ធដឹងពីអំពីកំណើតរបស់ខ្លួន ។

ជំពូកទី៣ ការកាត់កាលកូនស្មុំពេញលេញ និយាយអំពីមូលហេតុនៃការកាត់កាលអានុភាពនៃការកាកាលជាដើម។

# ជំពូកទី ១

# លក្ខណៈនៃការបង្កើតសម្ភ្ញ

# ក្នុងពេញលេញ

# ជំពូកទី ១ លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

ក្រមរដ្ឋប្បវេណីគឺជាច្បាប់មួយដែលបានបង្កើតនូវសិទ្ធិ និង ទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយបង្កើត និងកូនបង្កើតអោយមានចំណងគតិ្តយុត្តរវាងគ្នាទៅវិញទៅមក ប៉ុន្តែក្រៅពីទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និងកូនបង្កើត ក្រមរដ្ឋប្បវេណីក៏បានបង្កើតអោយមានរបបមួយ ដែលអនុញ្ញាតិអោយបុគ្គល គ្មានទំនាក់ទំនងញាតិលោហិតជាមួយនឹងគ្នា ក្លាយជាញាតិ និងមានចំណងគតិ្តយុត្តរវាងគ្នាទៅវិញទៅមក ដែលរបបមួយនោះត្រូវបានគេកំណត់ថា ជា ការសុំកូន ។ដោយសាការចង់ជួយសង្គ្រោះ ការអាណិតដល់កុមារដែលមានឪពុកម្តាយក្រីក្រ ឬកុមារកំព្រា ទើបធ្វើអោយពលរដ្ឋដែលគ្មានកូន សុំកុមារទាំងនោះយកមកចិញ្ចឹម ។ មានកុមារមិនតិចទេ ដែលមានសំណាងដោយការសុំនេះ ពួកគេបានរស់នៅក្នុងគ្រួសារមួយយ៉ាងកក់ក្តៅ ។

ការសុំកូន ត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ភាគទី៥ គន្លឹទី៧ ស្តីពីញាតិ ជំពូកទី៤ ផ្នែកទី២ ដែលកំណត់ពីការសុំកូន។

ការសុំកូនត្រូវបានចែកជា ២ ប្រភេទគឺ

- សុំកូនពេញលេញ
- សុំកូនធម្មតា

សុំកូនទាំងពីរនេះមានលក្ខខណ្ឌ និងអានុភាពខុសគ្នាដោយក្នុងនោះសុំកូនពេញលេញមានលក្ខខណ្ឌក្នុងការបង្កើតតឹងរឹងជាងសុំកូនធម្មតា ដូចជាករណីសុំកូនពេញលេញអាចបង្កើតបានតែចំពោះតែកុមារតូចៗ ដែលជាគោលការណ៍មានអាយុតិចជាង៨ឆ្នាំ និងអាចអាចបង្កើតចំពោះតែបុគ្គលដែលមានសហព័ទ្ធ ។ ដោយសារតែការសុំកូនពេញលេញនេះមានភាពលំបាក និងធំទូលាយយ៉ាងខ្លាំងក្នុងការបកស្រាយ ទើបយើងខ្ញុំសម្រេចចិត្តធ្វើការបកស្រាយតែទៅលើរបបនៃការសុំកូនមួយប្រភេទ គឺការ សុំកូនពេញលេញ ដើម្បីអោយការបកស្រាយមានភាពលំអិត និង ច្បាស់លាស់ ។ចំណុចសំខាន់ជាងគេនេះ តើការសុំកូននេះ ត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច និង អនុវត្តដោយរបៀបណាដើម្បីអោយមានអានុភាព និងត្រឹមត្រូវតាមច្បាប់ ។ ដូច្នេះ ដើម្បីអោយប្រធានបទនេះ មានភាពកាន់តែល្អ និង ច្បាស់យើង ខ្ញុំទាំងពីរនាក់ សុំលើកយកច្បាប់ មកបកស្រាយក្នុងប្រធានបទមួយនេះដែល ធ្វើការដកស្រង់ចេញពី ក្រមរដ្ឋប្បវេណី ដែលប្រកាសអោយប្រើនៅថ្ងៃ ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ និង ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីនៃរដ្ឋរប្បវេណីមិនមែនបណ្តឹង ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១០ កក្កដា ឆ្នាំ២០១០។

សុំកូនពេញលេញគឺជាការសុំអនីតិជនដែលមានអាយុក្រោម៨ឆ្នាំ[១]យកធ្វើជាកូនសុំដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើតហើយការសុំនេះត្រូវសម្រេចដោយតុលាការ។របបសុំកូនពេញលេញកូនសុំនឹងត្រូវកាត់ផ្តាច់នូវរាល់ទំនាក់ទំនងគតិយុត្តិទាំងអស់ជាមួយនឹងឪពុកម្តាយបង្កើតរបស់ខ្លួននិងផ្សារផ្ជាប់ទំនាក់ទំនងយ៉ាងពេញលេញជាមួយនឹងឪពុកម្តាយចិញ្ចឹមដូចគ្នានឹងកូបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។

ម៉្យាងវិញទៀតចំពោះរបបសុំកូនពេញលេញបុគ្គលដែលនឹងក្លាយជាឪពុកចិញ្ចឹមឬម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាង ទៀតមិន ក្លាយ ជាឪពុកឬក៏ម្តាយចិញ្ចឹម។មិនតែប៉ុណ្ណោះការបង្កើតសុំកូនពេញលេញ អាចធ្វើឡើងដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតរបស់ឪពុកម្តាយបង្កើតតាមពាក្យសុំរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន។ ចំពោះសុំកូននេះបង្កើតអានុភាពឲ្យមានចំណងញាតិលោហិតនិងសិទ្ធិ កាតព្វ កិច្ចក្នុងទំនាក់ទំនងញាតិហើយសុំកូននេះក៏ប្រឈមមុខនឹងការកាត់កាលដោយ មានមូលហេតុផ្សេងៗផង ដែរ [២]។

សុំកូនពេញលេញ សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និងកូនរវាងឪពុកម្តាយចិញ្ចឹមឬឪពុកចិញ្ចឹមឬម្តាយចិញ្ចឹមនឹងកូនសុំហើយបញ្ចប់សិទ្ធិនិងកាតព្វកិច្ចរវាងកូនសុំនិង ឪពុកម្តាយបង្កើត ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់ ខ្លួន។ ឲ្យអាចនិយាយបានម៉្យាងថាដោយបង្កើតសុំ កូនពេញលេញ កូនសុំត្រូវទទួលបានឋានៈដូចគ្នា នឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនិងត្រូវទទួលសិទ្ធិនិង ករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមបន្ថែមលើសពីនេះញាតិភាពរវាងកូន សុំនិងឪពុកម្តាយបង្កើតត្រូវបញ្ចប់ដោយកូនសុំពេញលេញលើកលែងចំពោះសហព័ទ្ធម្ខាងក្លាយជាឪពុកឬម្តាយ ចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។

យោងតាមការបកស្រាយខាងលើ យើងអាចនិយាយជារួមបានថាកាលណាបង្កើត សុំ កូនពេញលេញនាំ ឲ្យមានស្ថានភាពពីរកើតឡើង ទី១ គឺបង្កើតនូវទំនាក់ទំនង ឬញាតិភាពរវាង កូនសុំជាមួយឪពុកម្តាយចិញ្ចឹមដូច ជាកូនបង្កើត ពោលគឺបង្កើតសិទ្ធិ និងកាតព្វកិច្ចដូចកូន នឹងឪពុក ម្តាយបង្កើត។ ទី២ គឺបញ្ចប់ញាតិភាព ឬទំនាក់ ទំនងជាមួយឪពុកម្តាយបង្កើត ក៏ដូចជាញាតិលោហិត របស់ឪពុក ម្តាយបង្កើត។

លក្ខណៈនេះមិនមែនមានតែចំពោះភាគីម្ខាងៗនោះទេគឺមានទាំងចំពោះឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយ ចិញ្ចឹម ក៏ដូចជាចំពោះកូនចិញ្ចឹមដែរហេតុនេះលក្ខណៈនេះ នឹងលំអិត ចំពោះ ភាគីទាំង សងខាង។

អនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីមិនមែនជាបណ្តឹង ការបង្កើតសុំកូនពេញ លេញ គឺត្រូវឆ្លងកាត់ នីតិវិធីតុលាការ ដោយតុលាការដើរតួជាអ្នកពិនិត្យនូវលក្ខខណ្ឌសារជាតុ និង ចេញដីការ សម្រេច ។

---

១ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១០

២ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៦

## ផ្នែកទី១ : លក្ខខណ្ឌ ចំពោះម្ដាយឪពុកចិញ្ចឹម និង ចំពោះកូនសុំពេញលេញ

បើយោងតាមក្របខ័ណ្ឌរដ្ឋប្បវេណីឆ្នាំ២០០៧ ការសុំកូនពេញលេញអាច ប្រព្រឹត្តទៅ បាន លុះត្រាតែ ឪពុកម្ដាយចិញ្ចឹមទាំងពីរ ព្រមទាំងកូនចិញ្ចឹមមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ទៅតាម លក្ខខណ្ឌដែលច្បាប់បាន កំណត់ ហើយត្រូវបានតុលាការប្រកាសអនុញ្ញាតឲ្យមានការសុំ កូនពេញលេញ។ ការសម្រេចរបស់តុលាការទៅតាមពាក្យសុំ នឹងបញ្ចប់នូវរាល់ទំនាក់ ទំនងញាតិ ភាពរវាង ឪពុកម្ដាយជាមួយនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។

**ឧទាហរណ៍**: លោកស្រី បុប្ផាគឺជាស្ត្រីមេម៉ាយហើយមានកូនម្នាក់ឈ្មោះ រីទ្ធ ដែលមានអាយុ៥ឆ្នាំ ក្រោយមកនៅក្នុងឆ្នាំ2022 លោកបានរៀបអាពាហ៍ពិពាហ៍ជាថ្មីជាមួយនឹងបុរសម្នាក់ឈ្មោះ ដេត ក្រោយពីរៀបការរួចមក លោកមានបំណងចង់សុំកូនពេញលេញជាមួយនឹង រីទ្ធដែលត្រូវជាកូនរបស់លោកស្រីបុប្ផា។នៅក្នុងករណីនេះ លោកស្រីបុប្ផាជាម្ដាយបង្កើត រួចទៅហើយ នាងមិនអាចក្លាយជាម្ដាយចិញ្ចឹមនោះទេ ដូចនេះលោកដេតអាចក្លាយជាឪពុកចិញ្ចឹមរបស់រីទ្ធបាន។

បុគ្គលដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹមចាំបាច់បំផុតត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ចំពោះបុគ្គលដែលជាប្ដី ឬប្រពន្ធតែម្ខាងតែមិនអាចក្លាយជាឪពុកម្ដាយចិញ្ចឹមបានឡើយដោយសារការបង្កើតសុំកូនពេញលេញធ្វើឡើងក្នុងគោលបំណងផ្ដល់នូវគ្រួសារមួយដែលលំនឹងគ្រប់គ្រាន់សម្រាប់កុមារអភ័ព្វទើបទាមទារការសហការរវាងសហព័ទ្ធ ។ ប្រសិនបើសហព័ទ្ធតែម្ខាងហើយខ្វះការចូលរួមពីសហព័ទ្ធម្ខាងទៀតនោះគោលបំណងដែលផ្ដល់គ្រួសារមួយមានលំនឹងសម្រាប់កុមារអភ័ព្វនឹងមិនអាចសម្រេចបានឡើយ។ចំនួនកូនសុំក្នុង មាត្រា១១១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ បានកំណត់ថាគេ អាចសុំកូនបានតែពីរនាក់ប៉ុណ្ណោះ។បើកូនសុំនោះមានមួយណាស្លាប់គេអាចសុំកូនមួយនាក់ ទៀត។ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណីមិនមានមាត្រាណាមួយកំណត់ពីចំនួននៃកូនសុំឡើយ ហេតុនេះនៅពេលនេះក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានចូលជាធរមានតើចំនួនកូនសុំកំណត់យ៉ាងណា?

### កថាភាគទី១ : អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើង ទៅហើយ មានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០(ម្ភៃ)ឆ្នាំ [៣] ។ ខ្លឹមសារនៃមាត្រានេះ បានបង្ហាញពីលក្ខខណ្ឌ ត្រូវបានកម្រិត ពីអាយុអប្បបរមារបស់ឪពុកម្ដាយចិញ្ចឹម ដែលកំណត់ត្រឹម ២៥ ឆ្នាំ ពោលគឺ ឪពុកម្ដាយចិញ្ចឹមអាចមានសិទ្ធិ

៣ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០០៩

សុំកូនមកចិញ្ចឹមបាន លុះត្រាតែមាន អាយុតិចបំផុត ២៥ ឆ្នាំ ដោយត្រូវរក្សាគម្លាតអាយុរវាងឪពុកម្តាយចិញ្ចឹម និង អាយុកូនសុំដើម្បីមើលទៅអោយស្ថិតក្នុងភាពសមរម្យបន្តិច អោយដូចឪពុកម្តាយនិងកូន គឺយ៉ាងតិច២០ឆ្នាំដូចកំណត់ខាងលើ។

ការកំណត់អាយុនេះ មានគោលដៅចម្បង តម្រូវអោយឪពុកម្តាយចិញ្ចឹមមានអាយុច្រើនបន្តិច ដើម្បីមានភាពចាស់ទុំផ្នែករាងកាយ និងស្មារតីក្នុងការចិញ្ចឹមបីបាច់កូនដែលខ្លួនសុំមកចិញ្ចឹមនោះ ។

អាយុអប្បរមារបស់ឪពុកម្តាយចិញ្ចឹម និងគម្លាតអាយុសមរម្យរវាងឪពុកម្តាយ និងកូនបានសិក្សាអំពីទំនៀមទម្លាប់របស់កម្ពុជាដោយមានការចាំបាច់តម្រូវអោយមានភាណចាស់ទុំទាំងផ្នែកស្មារតី រាងកាយដើម្បីថែរក្សាជាក់ស្តែងនូវទារក ឬកូនក្មេង ។

នៅក្រមរដ្ឋប្បវេណីប៊ែលហ្សិកមាត្រា៣៤៥ និង៣៤៨ ទាមទារអោយមានអាយុលើសពី២៥ឆ្នាំត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងហោច១៥ឆ្នាំ ។

ម្យ៉ាងវិញទៀតដោយហេតុថាប្រទេសជាច្រើនមានគោលបំណងសុំកូនពេញលេញគឺមានការបីបាច់ថែរក្សាថែទាំកុមារដូចគ្នាទៅនឹងឪពុកម្តាយនិងកូនបង្កើត ដូច្នេះហើយទើបមានប្រទេសជាច្រើនទាមទារអោយមានគម្លាតអាយុប្រហែលគ្នាចាប់ពី១០ ទៅ ១៨ឆ្នាំ។

**កថាភាគទី២ : ស្ថានភាពគ្រួសារ**

បុគ្គលដែលក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ [៤] ។ ត្រូវមានការ សហការ និងឯកភាពរវាងប្តីព្រន្ធ បើមិនដូច្នេះទេប្តី ឬប្រពន្ធតែម្ខាងមិនអាច ក្លាយ ជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬម្តាយចិញ្ចឹមនៃ កូន នោះតែលើកលែងចំពោះ សហព័ទ្ធក្លាយជាឪពុកឬម្តាយចិញ្ចឹមនៃកូនបង្កើតរបស់ សហព័ទ្ធ ម្ខាង ទៀត។

ដោយហេតុថា ការសុំកូនពេញលេញ គឺជាផ្តល់គ្រួសារ ដែលតម្រូវអោយមានវត្តមានទាំងឪពុកម្តាយដែលអាចផ្តល់សុភមង្គល និងភាពកក់ក្តៅដល់កុមារទាំងឡាយ ដែលខ្វះខាតនូវជីវភាពអោយទទួលបានឱកាសដូចជាកុមារដទៃទៀតដែរ ។ ដូចនេះបានជាការសុំកូនពេញលេញនេះ តម្រូវអោយមានការ សហការគ្នារវាងប្តីប្រពន្ធទើបជាការប្រសើរដើម្បីអោយកូនសុំមានឪពុកនិងម្តាយ។

---

៤ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០០២ កថាខណ្ឌទី៥

**កថាភាគទី៣ : ជីវភាពរបស់ឪពុកម្ដាយចិញ្ចឹម**

តុលាការត្រូវពិចារណាលើស្ថានភាព ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើក្នុងការគ្រប់គ្រងថែរក្សារកុមារដែលនឹងក្លាយជាកូនសុំជាគោលការយ៉ាងតិច ៦ (ប្រាំមួយ) ខែ។ មានន័យថាក្នុងករណីចាំបាច់ មុននឹងធ្វើសេចក្ដីសម្រេចសេចក្ដីថាអនុញ្ញាតឲ្យមាន ការ បង្កើតស្នុំកូនពេញលេញតុលាការត្រូវតែកំណត់ឲ្យឪពុកម្ដាយចិញ្ចឹមធ្វើការចិញ្ចឹមកូននោះក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ [5] ដើម្បីត្រួតពិនិត្យ និង ពិចារណាថាឪពុកម្ដាយពិតជាមានលក្ខណៈសម្បត្តិ លទ្ធភាព និងមានសមត្ថភាព គ្រប់គ្រាន់ក្នុងការចិញ្ចឹមបិបាច់ថែរក្សាកុមារឬទេ ?

ចំនួនកូនសុំក្នុង មាត្រា១១ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ បានកំណត់ថាគេ អាចសុំកូនបានតែពីរនាក់ប៉ុណ្ណោះ។បើកូនសុំនោះមានមួយណាស្លាប់គេអាចសុំកូនមួយនាក់ ទៀត។ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណីមិនមានមាត្រាណាមួយកំណត់ពីចំនួននៃកូនសុំឡើយ ហេតុនេះនៅពេលនេះក្រមរដ្ឋប្បវេណីឆ្នាំ២០០៧បានចូលជាធរមានតើចំនួនកូនសុំកំណត់យ៉ាងណា ?

**កថាភាគទី៤ : អាយុរបស់កូន**

ជាគោលការណ៍កូនសុំត្រូវមានអាយុយ៉ាងច្រើន ៨(ប្រាំបី)ឆ្នាំ [6] ហើយស្នុំកូនពេញលេញ បង្កើតឡើងដើម្បីកសាងទំនាក់ទំនងដោយយកឪពុកម្ដាយចិញ្ចឹមមកធ្វើជាមេបាតែមួយគូដូចគ្នាជាមួយនឹងទំនាក់ទំនងជាមួយកូនបង្កើតនោះ កូនសុំគួរតែមានអាយុក្រោមអាយុចូររៀន ផ្ទុយមកវិញបើកូនសុំជាអនីតិជនដែលមានអាយុច្រើនជាងនេះរបបស្នុំកូនពេញលេញពុំអាចធ្វើទៅបានឡើយ។

ទាក់ទងនឹងកូនសុំ យោងទៅតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារគេអាចសុំកូនត្រឹម២នាក់បានប៉ុណ្ណោះ ប្រសិនបើកីននោះមានមួយណាស្លាប់គេអាចស្នុំកូនមួយនាក់ទៀតបាន។

សេចក្ដីព្រាងច្បាប់នេះរៀបចំឡើងដើម្បីអោយមានការបីបាច់ថែរក្សាកូនស្នុំអោយដូចជាកូនបង្កើត ចាំបាច់ត្រូវកម្រិតចំនួនកុមារដែលជាកូនស្នុំពេញលេញ ។ម្យ៉ាងវិញទៀតតាមរយៈការស្នុំកូននេះដែរត្រូវតែមានអាយុក្រោមអាយុចូលរៀន។

---

៥ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៣

៦ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១០

**កថាភាគទី៥ : ស្ថានភាពរបស់កូន**

ស្មុំកូនពេញលេញត្រូវបានបង្កើតឡើងនៅក្នុងករណីដែលមានការពិបាកខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងកុមារដែលនឹងក្លាយជាកូនសុំដោយឪពុកម្តាយបង្កើត ឬស្ថានភាពពិសេសផ្សេងៗទៀតដែលមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ[៧] និងស្ថានភាព ដែលនឹងក្លាយជាឪពុកចិញ្ចឹមបានធ្វើក្នុងការគ្រប់អាយុយ៉ាងតិច ៦ខែ។

កត្តាដែលល្អប្រសើរ ដើម្បីអាចបីបាច់ថែរក្សារកូនសុំអោយដូចកូនបង្កើត ចាំបាច់គួរតែមានការកំណត់ចំនួនកុមារដែលជាកូនសុំតាមស្មុំកូនពេញលេញ។ បើមានចំនួនច្រើនអាចមានការពិបាកនៅក្នុងការទំនុកបម្រុងប្រសិនបើលទ្ធភាពទ្រព្យធនរបស់ឪពុកម្តាយចិញ្ចឹមមានភាពខ្សត់ខ្សោយនោះ។កូនសុំត្រូវតែជាកុមារដែលអភព្វ័ហើយដែលមានគ្រួសារមិនអំណោយផលសំរាប់ការរស់នៅនិងមិនដែលមើលថែគឺកុមារមិនអាចទទួលបាននូវគ្រួសារល្អមួយដែលមានលទ្ធភាពគ្រប់គ្រាន់ការទទួលបាននូវការចិញ្ចឹមថែរក្សាល្អពីឪពុកម្តាយបង្កើតសមស្របដូចកុមារឯទៀត។

ចំពោះស្ថានភាពកុមារគេពិនិត្យលើទិដ្ឋភាពរបស់កុមារនៅក្នុងករណីកុមារមានភាពពិបាកខ្លាំងមានការបាត់ខ្លួនជាដើមមានស្មារតីធ្ងន់ធ្ងរជាដើម។ម្យ៉ាងវិញទៀតការគ្រប់គ្រងកុមាររបស់ឪពុកម្តាយអាចនឹងមានការបំពានផ្លូវចិត្ត ផ្លូវកាយតាមរយះពាក្យសម្តីឬអាចជាការមិនយកចិត្តទុកដាក់នៅក្នុងការមើលថែកុមារ ។បន្ថែមទៀតនោះដោយគិតពីភាពចាំបាច់ដើម្បីផលប្រយោជន៍របស់កុមារអាចធ្វើអោយកុមារមានភាពល្អប្រសើរទាំងផ្លូវចិត្តនិងផ្លូវកាយនិងការផ្គត់ផ្គង់ចាំបាច់កុមារបានល្អជាងឪពុកម្តាយបង្កើត។

## **ផ្នែកទី២ : លក្ខខណ្ឌ ផ្សេងៗទៀត**

**កថាភាគទី១ : ការយល់ព្រមពីម្តាយឪពុក បង្កើត**

ការយល់ព្រមពីឪពុកម្តាយបង្កើតដើម្បីបង្កើតស្មុំកូនពេញលេញត្រូវមានការព្រមពីឪពុកម្តាយបង្កើត ឬអាណាព្យាបាលចំពោះនីតិជនរបស់កុមារដែលក្លាយជាកូនសុំនោះ។ ប្រសិនបើ ឪពុកម្តាយបង្កើតឬអាណាព្យាបាលស្របច្បាប់មិនអាចបង្ហាញឆន្ទះឬក៏មានការធ្វើបាបពីឪពុកម្តាយ ធ្ងន់ធ្ងរ ការបោះបង់កូនដោយទុច្ចរិត ឬហេតុផលផ្សេងៗដែលបំពានផលប្រយោជន៍ នៃកូនសុំ នោះយ៉ាងធ្ងន់ធ្ងរ បញ្ញាត្តិខាងលើមិនអាចអនុវត្តនបានឡើយ។

គោលបំណងនៃការស្មុំកូនពេញលេញដើម្បីជាផលប្រយោជន៍របស់កុមារជាចម្បងហើយតម្រូវអោយមាន

---

៧ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១២

ការផ្តាច់ទំនាក់ទំនងគតិ្តយុត្តជាមួយឪពុកម្តាយបង្កើតដោយមានគោលបំណងយកកូនសុំនោះមករស់ជាមួយខ្លួន នៅក្នុងមានជាឪពុកម្តាយជាធម្មតាអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមពីឪពុកម្តាយបង្កើត ។

ទោះបីលក្ខខណ្ឌដូចជាបានកំណត់ខាងលើនេះ ប្រសិនបើមានការពិបាកក្នុងការពឹងកភាពឪពុកម្តាយបង្កើត ឬក្នុងករណីដែលជំទាស់របស់ឪពុកម្តាយបង្កើតបានបំពានយ៉ាងធ្ងន់ធ្ងរដល់ប្រយោជន៍កុមារទោះបីដឹងថាខ្លួនគ្មានលទ្ធភាពនិងផ្គត់ផ្គង់នូវជីវភាពដល់កុមារដោយចេតនាទុចរិតណាមួយ បើផលប្រយោជន៍របស់កូនស្មុំតម្រូវពេលគឺបើកូនសុំរស់នៅជាមួយឪពុកម្តាយចិញ្ចឹមមានអនាគតរុងរឿង ការឯកភាពពីឪពុកម្តាយបង្កើតក្នុងករណីនេះ មិនចាត់ទុកជាកត្តាសំខាន់ទេមានន័យថាទោះបីឪពុកម្តាយបង្កើតបដិសេធ ការស្មុំកូនករណីនេះក៏ប្រព្រឹត្តទៅបានដែរ។

នេះជាករណីពិសេសមួយក្នុងការសម្រេចចិត្ត ពីករណីនៃការស្មុំកូនពេញលេញដោយគិតពិចារណាលើផលប្រយោជន៍របស់កូនសុំជាចម្បង។ហើយការស្មុំកូនអាចប្រព្រឹត្តទៅបាន បើទោះបីឪពុកម្តាយបង្កើតបដិសេធនូវការស្មុំកូននេះក៏ដោយ កាលបើផលប្រយោជន៍របស់កូនតម្រូវនោះ ការស្មុំកូននៅតែអាចធ្វើទៅបានសម្រាប់ករណីមួយនេះ។

**កថាភាគទី២ : លទ្ធភាពរបស់ម្តាយឪពុកបង្កើត**

ស្មុំកូនពេញលេញត្រូវបានបង្កើតឡើង នៅក្នុងករណីពិបាកយ៉ាងខ្លាំង ឬមិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំដោយឪពុកម្តាយបង្កើតឬស្ថានភាពពិសេសផ្សេងៗទៀតបើយល់ឃើញមានភាពចាំបាច់ពិសេសដើម្បីបំរើផលប្រយោជន៍កូននោះ។ឪពុកម្តាយបង្កើតបាត់ខ្លួន ឬមានវិបត្តិផ្នែករាងកាយ មានជីវភាពក្រីក្រខ្លាំងដែលមិនអាចចិញ្ចឹម បីបាច់ថែរក្សាកូនបានល្អ ឬឪពុកម្តាយធ្វើបាបកូន ឬបោះបង់កូនចោល។ បន្ថែមលើនេះ មាត្រា ១០១៣ (អំឡុងពេលសាកល្បងចិញ្ចឹម) នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានឱ្យតុលាការ ពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹង ក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំផងដែរ។

**កថាភាគទី៣ : ផលប្រយោជន៍របស់កូន**

កត្តាដែលបង្កើតឲ្យមានអានុភាពរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹមគឺកូនស្មុំត្រូវការតែកាត់ផ្តាច់ញាតិភាពជាមួយឪពុកម្តាយបង្កើតហើយកូនស្មុំត្រូវតែទទួលបានសិទ្ធិនិងករណីកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែររីឯអំណាចមេបាត្រូវប្រគល់ទៅឲ្យឪពុកម្តាយចិញ្ចឹម។

**ឧទាហរណ៍**:លោក រតនាជាពោះម៉ាយ មានកូនមួយនាក់ដែលជាអនីតិជន ដោយសារតែលោកមានជីវភាពខ្វះខាតលោកបានសម្រេចចិត្តអោយកូនរបស់លោកដើរសុំទានគេនៅតាមផ្លូវដើម្បីយកប្រាក់មកចិញ្ចឹមគាត់ដោយមិនបានអោយកូនទៅសាលារៀនដើម្បីរៀនសូត្រដូចកូនគេដទៃនោះទេ។អំពើបែបនេះជាមូលហេតុចាត់ទុកថាប៉ះពាល់ទៅដល់ផលប្រយោជន៍របស់កូនយ៉ាងធ្ងន់ធ្ងរ ដែលមានន័យថាតុលាការអាចបង្កើតការសុំកូនពេញលេញបានទោះបីជាពុំមានការយល់ព្រមពីឪពុកម្តាយបង្កើតក៏ដោយ។តុលាការសម្រេចចិត្តបង្កើតកូនស្មុំនេះលុះត្រាតែយល់ឃើញ ករណីឪពុកម្តាយបាត់ខ្លួន មានវិបិត្តផ្នែករាងកាយ មានជីវភាពក្រីក្រខ្លាំងដែលមិនអាចចិញ្ចឹមកូនបានដែលជាហេតុអាចធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់កុមារ ។

## កថាភាគទី៤ : លក្ខខណ្ឌផ្សេងៗមួយចំនួនទៀត

ក្នុងមាត្រា១១២នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារបានកំណត់ថាដើម្បីឲ្យការសុំកូនសម្រេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្តាយឬអ្នកអាណាព្យាបាលនៃកូនសុំនោះបើជាទារកឬកុមារដែលគេបោះបង់ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំឬសង្កាត់នៅពេលដែលមានជនណាម្នាក់រើសបានទារកត្រូវយកទៅប្រគល់ឲ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងឃុំសង្កាត់នៅទីកន្លែងដែលរើសបានទារកនោះ។

ក្នុងអំឡុងពេលដែលទារកឬកុមារដែលគេបោះបង់ចោលស្ថិតក្នុងការថែរក្សារបស់មន្ត្រីអត្រានុកូលដ្ឋានបើមានជនណាសុំទារកដែលត្រូវបានរើសបាននោះជាកូនចិញ្ចឹមត្រូវយកនាមត្រកូលអ្នកសុំ។ប៉ុន្តែបើពុំមានជនណាម្នាក់សុំទារកដែលរើសបានធ្វើជាកូនចិញ្ចឹមទេនោះមន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនទារកនោះដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនិងកំណត់ហេតុស្តិពីការប្រគល់ទារកទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ

កុមារ។

ការសុំកូនឬទារកពីឪពុម្តាយជាកូនចិញ្ចឹមត្រូវអនុវត្តទៅតាមនីតិវិធីដូចមានចែងក្នុងច្បាប់និងលិខិបទដ្ឋានជាធរមាន។កំឡុងពេលនៃការចិញ្ចឹមសាកល្បងដើម្បីបង្កើតស្មុំកូនពេញលេញតុលាការត្រូវពិចារណាទៅលើស្ថានភាពបុគ្គលដែលក្លាយទៅជាឪពុលចិញ្ចឹមឬម្តាយចិញ្ចឹមឬឪពុកម្តាយចិញ្ចឹមក្នុងការថែរក្សាកុមារដែលនឹងក្លាយជាកូនស្មុំយ៉ាងតិច ៦ខែ។

ជាគោលការណ៍ ការស្មុំកូនពេញលេញ មិនមែនបញ្ចប់ត្រឹមបំពេញលក្ខខណ្ឌគ្រឹះខាងលើតែម៉្យាងនោះទេ ដោយហេតុថា ស្មុំកូនប្រភេទនេះ តម្រូវអោយមានការកាត់ផ្តាច់ទំនាក់ទំនងគតិយុត្តជាមួយឪពុកម្តាយបង្កើត ជាពិសេសត្រូវឆ្លងកាត់នីតិវិធីរបស់តុលាការ។ ដូចនេះទម្រង់នៃការស្មុំកូនប្រភេទនេះ គឺចាំបាច់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ទើបមានសុពលភាពតាមផ្លូវច្បាប់។

អំឡុងពេលបង្កើតស្មុំកូនពេញលេញតុលាការពិចារណាលើស្ថានភាពដែលបុគ្គលក្លាយជាឪពុកមកដាយចិញ្ចឹមសាកល្បងចិញ្ចឹមរយៈពេល៦ខែ (មាត្រា១០១៣នៃក្រមរដ្ឋប្បវេណី) មាត្រានេះបានបញ្ញត្តិអំពីការសាល្បងចិញ្ចឹមដើម្បីពិនិត្យមើលថាតើឪពុកម្ដាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរឬទេ ហើយអាចបង្កើតទំនាល់ទំនងមួយល្អជាមួយកូនសុំនិងឆ្លើយតបនឹងផលប្រយោជន៍របស់កុមារបានដែរឬទេ ឬយ៉ាងណា។

អំឡុងពេលសាកល្បងគឺជាអំឡុងពេលដាច់ខាត់ ដែលតុលាការត្រូវតែកំណត់ដើម្បីអាចសម្រេចស្មុំកូនពេញលេញ ។ ពីព្រោះអំឡុងពេលសាកល្បងគឺជាអំឡុងពេល ដែលអាចឱ្យតុលាការពិចារណាថាតើឪពុកម្ដាយចិញ្ចឹមនិងកូនសុំអាចរស់នៅចុះសម្រុងគ្នាដែរឬទេ។

បើយើងពិនិត្យខ្លឹមសារនៃមាត្រានេះហាក់ដូចជាទទួលស្គាល់ថាអំឡុងពេលសាកល្បងត្រូវធ្វើឡើងក្រោយពេលដាក់ពាក្យសុំហេតុនេះ អង្គហេតុចិញ្ចឹមដែលបានធ្វើមុនពេលដាក់ពាក្យមិនមែនជាអំឡុងពេលសាកល្បងទេ ហេតុនេះការបកស្រាយចំពោះមាត្រានេះអាស្រ័យលើភាគីកម្ពុជា។

យោងតាមមាត្រា១៦នៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងបុគ្គលដែលអាចដាក់ពាក្យសុំត្រូវតែជាជនពាក់ព័ន្ធដែលអាចក្លាយជាប្រធាននៃសិទ្ធនិងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

នៅក្នុងមាត្រា១០១១ការយល់ព្រមពីឪពុកម្ដាយនៃក្រមរដ្ឋប្បវេណីដំណើតការនៃការជំនុំជម្រះលើពាក្យសុំតុលាការនឹងសាកសួរឪពុកម្ដាយបង្កើតក្នុងនាមជាជនពាក់ព័ន្ធអំពីការឯកភាពអោយបង្កលតរបបស្មុំកូនពេញលេញ។

ទម្រង់ពាក្យសុំ ត្រូវធ្វើដោយអនុឡោមតាមច្បាប់ស្ដីពីនីតិវិធីមិនមែនជាបណ្ដឹងរដ្ឋប្បវេណីដោយពាក្យសុំអោយតុលាការចេញដីកាសម្រេចចាប់ផ្ដើមស្មុំកូនត្រូវសរសេរពីចំណុចដូចខាងក្រោម:

- អត្តសញ្ញាណប័ណ្ណជនដែលពាក់ព័ន្ធ ឈ្មោះ អាស័យដ្ឋានអ្នកដាក់ពាក្យសុំ(របស់ឪពុកម្ដាយចិញ្ចឹម) និងភាគីម្ខាងទៀត (ឪពុកម្ដាយបង្កើត និងកូនសុំ)
- ខ្លឹមសារសេចក្ដីសម្រេច: សុំអោយតុលាការចេញសេចក្ដីសម្រេចចាប់ផ្ដើមស្មុំកូន ឪពុកម្ដាយចិញ្ចឹម ឈ្មោះ និងកូនសុំ
- អង្គហេតុទាមទារ : ត្រូវបង្ហាញអោយតុលាការយល់ដឹងអំពីស្ថានភាពលំបាករបស់កុមារ
- ឧបសម្ព័ន្ធពាក្យសុំ: សេចក្ដីចម្លងសំបុត្រកំណើតរបស់ឈ្មោះ អ្នកដាក់ពាក្យសុំនិងកូនសុំ ។

យោងទៅច្បាប់ដែលបានចែងខាងលើទីកន្លែងដាក់ពាក្យសុំត្រូវដាក់នៅខាងឪពុកម្ដាយចិញ្ចឹមហើយអ្នកដាក់ពាក្យបង់ពន្ធត្រូវបង់ពន្ធចំនួន៥០០០(ប្រាំពាន់)រៀល។

## ផ្នែកទី៣៖ ការវិនិច្ឆ័យសេចក្ដី និងការចេញដីកាសម្រេច

ជាគោលការណ៍ ការបង្កើតអោយមានការសុំកូនពេញលេញ គឺត្រូវមានគោលការណ៍នៃការវិនិច្ឆ័យច្បាស់លាស់ ។ ការកំណត់បែបនេះធ្វើឡើងដើម្បីការពារកុមារ ដោយជៀសវាងការស្នើសុំ បង្កើតការសុំកូនពេញលេញ ក្នុងគោលបំណងទុច្ចរិតណាមួយពីសំណាក់ឪពុកម្ដាយចិញ្ចឹម ពោលគឺមិនមានចេតនាល្អ ក្នុងការសុំកូននោះយកមកចិញ្ចឹមឡើយ ។ អាស្រ័យហេតុនេះ បានជាច្បាប់កំណត់ពីលក្ខខណ្ឌយ៉ាងច្បាស់លាស់នៃការបង្កើតការសុំកូនពេញលេញ ដើម្បីធ្វើជាមូលដ្ឋានអោយតុលាការពិចារណា ។

សុំកូនពេញលេញ ត្រូវបានបង្កើតឡើងនៅក្នុងករណីដែលមានការលំបាកយ៉ាងខ្លាំង ឬ មិនសមរម្យក្នុងការគ្រប់គ្រង ថែរក្សាកុមារដែលនឹងក្លាយជាកូនសុំដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងទៀត បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ ។

មាត្រានេះ(១០១២នៃក្រមរដ្ឋប្បវេណី)បានអំពីមូលហេតុវិនិច្ឆ័យនៅក្នុងករណីដែលតុលាការបង្កើតសុំកូន បើសិនជាតុលាការយល់ឃើញថាមិនសមរម្យអោយឪពុកម្តាយគ្រប់គ្រងថែរក្សាកូនដូចជាករណីឪពុកម្តាយបាត់ខ្លួន មានវិបត្ត ឪពុកម្តាយធ្វើបាប ឬបោះបង់កូនចោលហើយយល់ឃើញថាដើម្បីផលប្រយោជន៍កុមារចាំបាច់ត្រូវតែបញ្ចប់ញាតិភាពជាមួយឪពុកម្តាយនោះហើយបង្កើតសុំកូនជាមួយឪពុកម្តាយចិញ្ចឹមទើបតុលាការអាចអាចសម្រេចសុំកូនបាន។

យោងតាមមាត្រា៨នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុបបានកំណត់ថាអាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការប្រកាសសុំកូនបានតែនៅក្នុងករណីដែលជឿជាក់ថាការសុំកូននោះនឹងអាចធានាទៅបានដល់ប្រយោជន៍របស់កុមារប៉ុណ្ណោះដោយផ្តល់អោយនូវកុមារនូវគ្រួសារដែលមានស្នេហភាពនិងភាពសុខុដុមរមនា នឹងសេចក្តីសុខ។

## កថាភាគទី១ ការពិនិត្យលើភាពចាំបាច់នៃការបង្កើតការសុំកូន

ក្រោយពីបានទទួលពាក្យសុំ និងបានពិនិត្យឃើញថាពាក្យមានលក្ខណៈត្រឹមត្រូវហើយ តុលាការត្រូវធ្វើការ វិនិច្ឆ័យលើពាក្យសុំ ដើម្បីចេញសេចក្ដីសម្រេច។ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយឆន្ទានុសិទ្ធរបស់ខ្លួន ដែលាការស្រាវជ្រាវអង្គហេតុ និងការពិនិត្យភស្តុតាងនានា[៨]។ នៅក្នុងសំណុំរឿងសុំកូនពេញលេញ អង្គហេតុដែលតុលាការចាំបាច់ត្រូវស្រាវជ្រាវ ពិនិត្យ និងផ្ទៀងផ្ទាត់ មុននឹងឈានដល់ការសម្រេចសេចក្ដីមានដូចជា៖

១.ក្នុងករណីនៃការសុំកូនដោយសហការរវាងប្ដីប្រពន្ធ តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា អ្នកដាក់ពាក្យសុំមានសហព័ទ្ធ ហើយបានដាក់ពាក្យសុំដោយសហការ។

៨ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីនៃរដ្ឋប្បវេណីមិនមែនបណ្ដឹង ដែលត្រូវបានប្រកាសអោយប្រើនៅថ្ងៃទី ១០ កក្កដា ឆ្នាំ២០១០ មាត្រា២៧

២.ក្នុងករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនសហព័ទ្ធតែម្ខាងទៀត នោះ តុលាការត្រួតពិនិត្យអង្គហេតុដែលបញ្ជាក់អំពីចំណុចនេះដោយហេតុថា នេះជាករណីអញ្ញត្រកម្មនៃគោលការណ៍សុំកូនពេញលេញដោយសហការ។

៣.តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា ឪពុកម្តាយចិញ្ចឹមមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ និងមានគម្លាតអាយុច្រើនជាងកូនសុំយ៉ាងតិច២០ឆ្នាំ។

៤.តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា កូនសុំមានអាយុតិចជាង ៨ឆ្នាំ។

៥. តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់អំពីការយល់ព្រមពីឪពុកម្តាយបង្កើតរបស់កូនសុំ។

៦.ក្នុងករណីដែលគ្មានការយល់ព្រមពីឪពុកម្តាយបង្កើត តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់អំពីករណីដែលឪពុកម្តាយបង្កើតនោះមិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ឬ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំ

នោះយ៉ាងធ្ងន់ធ្ងរបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរ។

៧.តុលាការត្រូវពិនិត្យទៅលើអង្គហេតុដែលបញ្ជាក់ថា មានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យក្នុងការគ្រប់គ្រងមើលថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត ព្រមទាំងមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍កុមារនោះ។

៨ ស្ថានភាពផ្លូវកាយនិងផ្លូវចិត្តស្ថានភាពជីវភាពនិងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ

៩ វិជ្ជាជីវៈនិងប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលទូទៅនិងអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងទៅនឹងផលប្រយោជន៍រវាងអ្នកអាណាព្យាបាលទូទៅនិងជននៅក្រោមអាណានិងស្ថានភាពទាំងស្រុង។

១០.ក្នុងករណីដែលជ្រើសតាំងអ្នកអាណាព្យាបាលទូទៅចំពោះអនីតិជនតុលាការអាចយកអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនមកជ្រើសតាំងជាអ្នកអាណាព្យាបាលទូទៅតុលាការត្រូវកំណត់អំពីការបែងចែកកិច្ចការរបស់អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

អង្គហេតុទាំងអស់ខាងលើ គឺជាលក្ខខណ្ឌគតិយុត្តដែលក្រមរដ្ឋប្បវេណី តម្រូវក្នុងការបង្កើតសុំកូនពេញលេញ ហើយដើម្បីអាចបញ្ជាក់ពីភាពត្រឹមត្រូវ និងពិតប្រាកដ ឬអត្ថិភាពនៃអង្គហេតុខាងលើបាន តុលាការចាំបាច់ត្រូវតែធ្វើការពិនិត្យភស្តុតាងជាឯកសារផ្សេងៗ ដែលអ្នកដាក់ពាក្យសុំបានដាក់ជូនតុលាការ ឬ តុលាការតម្រូវឲ្យដា

ក់។ ឯកសារទាំងនោះមានដូចជា ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ ឯកសារបញ្ជាក់ពីអត្តសញ្ញាណ ប្រវត្តិរូបកូនសុំ និង ឯកសារបញ្ជាក់ពីការយល់ព្រមរបស់ឪពុកម្តាយបង្កើតជាដើម។

ក្រៅពីការពិនិត្យភស្តុតាងជាឯកសារ តុលាការអាចធ្វើការសាកសួរភាគីដែលពាក់ព័ន្ធ ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់។ ជាលក្ខណៈពិសេស នៅក្នុងសំណុំរឿងសុំកូនពេញលេញ តុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ដោយហេតុថារឿងក្តីសុំកូនពេញលេញ ចាំបាច់ត្រូវរក្សានូវការសម្ងាត់ផ្ទាល់ខ្លួនយ៉ាងខ្លាំង ហើយមិនចាំបាច់មានភាពចំពោះមុខ និងសាធារណៈភាពនោះទេ។អាស្រ័យហេតុនេះ តុលាការមិនបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពោលគឺតុលាការអាចគ្រាន់តែធ្វើការសាកសួរភាគី ដើម្បីផ្តល់ឱកាសឲ្យភាគីអាចចូលរួមនីតិវិធីនេះជាការគ្រប់គ្រាន់ហើយ។

## កថាភាគ ទី២ ការចេញសេចក្តីសម្រេច

បន្ទាប់ពីបានធ្វើការវិនិច្ឆ័យតាមរយៈការពិនិត្យអង្គហេតុ និង ការពិនិត្យភស្តុតាងចប់សព្វគ្រប់តុលាការត្រូវពិចារណាលើស្ថានភាព នៃការចិញ្ចឹមសាកល្បងទៅលើបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍យ៉ាងតិច ៦ (ប្រាំមួយ) ខែ[៩] ដើម្បីឲ្យដឹងថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ ឬចុះសម្រុងគ្នា និងអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរឬយ៉ាងណា។ ទោះបីជាយ៉ាងនេះក្តីតុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីរយៈពេលសាកល្បងនេះ។

ជាចុងក្រោយ តុលាការត្រូវចេញ ដីកាសម្រេច ដែលអាចជាដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញ ឬដីកាសម្រេចលើកចោលពាក្យសុំ[១០]។ តុលាការ ត្រូវចេញដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញក្នុងករណីដែលតុលាការបានពិចារណាឃើញថា ភាគីពាក់ព័ន្ធបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់តម្រូវ និងមានមូលដ្ឋានវិនិច្ឆ័យគ្រប់គ្រាន់ដើម្បីបង្កើតសុំកូនពេញលេញ។ផ្ទុយទៅវិញ យោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹងតុលាការ។

ត្រូវចេញដីកាសម្រេចអំពីពាក្យសុំនៃសុំកូនពេញលេញ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់អង្គហេតុ និងភស្តុតាងរួចមក ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនៃសុំកូនពេញលេញ មិនបានបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

---

៩ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើ ឆ្នាំ២០០៧ មាត្រា ១០១៣

១០ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីនៃរដ្ឋប្បវេណីមិនមែនបណ្តឹង មាត្រា២ និងមាត្រា ៨

១.លក្ខខណ្ឌសម្រាប់ឪពុកម្តាយចិញ្ចឹម តាមមាត្រា១០០៨ និងមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី

២.លក្ខខណ្ឌសម្រាប់កូនសុំ តាមមាត្រា១០១០ នៃក្រមរដ្ឋប្បវេណី

៣.ការបង្ហាញឆន្ទៈយល់ព្រមពីសំណាក់ឪពុកម្តាយបង្កើត តាមមាត្រា១០១១ នៃក្រមរដ្ឋប្បវេណី

៤.មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ តាមមាត្រា១០១២ នៃក្រមរដ្ឋប្បវេណី

ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនៃសុំកូនពេញលេញនេះមិនបានបំពេញនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងឡាយដែលបានរៀបរាប់ពីខាងលើ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំ និងទុកសិទ្ធិឲ្យភាគីអ្នកដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងជំទាស់។

ដីកាសម្រេចអំពីសុំកូនពេញលេញ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវសរសេរ អំពីសំអាងហេតុនិងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមទទួលបន្ទុកត្រូវចុះហត្ថលេខាលើដីកាសម្រេចនេះ។ ដីកាសម្រេចអំពីសុំកូនពេញលេញ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ដែលរួមមាន អ្នកដាក់ពាក្យសុំ កុមារដែលនឹងក្លាយជាកូន និងឪពុកម្តាយបង្កើត។ តែបើជាដីកាសម្រេចលើកចោលពាក្យសុំការជូនដំណឹងនឹងត្រូវធ្វើចំពោះតែអ្នកដាក់ពាក្យសុំប៉ុណ្ណោះ។

ដីកាសម្រេចអំពីសុំកូនពេញលេញត្រូវបានចូលជាស្ថាពរ នៅពេលអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងហួស ឬ ពេលដែលតុលាការនៃបណ្តឹងជំទាស់ដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចអំពីពាក្យបណ្តឹងជំទាស់ នេះបើយោងតាមមាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ដើម្បីអាចប្រើប្រាស់បានតាមផ្លូវច្បាប់ ក្រោយការចូលជាស្ថាពរនៃដីកាសម្រេចអំពីសុំកូនពេញលេញ បណ្តាភាគីដែលពាក់ព័ន្ធត្រូវសុំបញ្ជាក់អំពីការចូលស្ថាពរនៃដីកាសម្រេចនេះផងដែរ។

# ជំពូកទី២

# អនុភាព ក្រោយដីកាសម្រេចសុំកូនពេញលេញចូលជាស្ថាពរ

# ជំពូកទី២

## អានុភាព ក្រោយដីកាសម្រេចសុំកូនពេញលេញចូលជាស្ថាពរ

ក្រោយពីដីកាសម្រេចសុំកូនពេញលេញរបស់តុលាការបានចូលជាស្ថាពរហើយ នោះអានុភាពនសុំកូនពេញលេញនឹងកើតមានចំពោះគូភាគី រួមមាន អានុភាពចំពោះឪពុកម្តាយបង្កើត និងកូនសុំ និងអានភាពចំពោះឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលអានុភាពចម្បងដ៏សំខាន់គឺ ការបញ្ចប់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតតែការបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើតពុំមានអានុភាពប្រតិសកម្មឡើយពោលគឺពុំមានអានុភាពទៅលើអតីតកាលឡើយ វាមានអានុភាពឆ្ពោះទៅមុខ គិតចាប់ពីថ្ងៃដែលបានបញ្ចប់។

ក្រោយអំពីដីកាសម្រេចបង្កើតសុំកូនពេញលេញបានចូលជាស្ថាពរ នោះនឹងបង្កើតអានុភាពនៃទំនាក់ទំនងសុំកូនចំពោះបុគ្គលដែលពាក់ព័ន្ធដូចជា កូនសុំ ឪពុកម្តាយចិញ្ចឹម ញាតិរបស់ឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត រួមទាំងញាតិរបស់ឪពុកម្តាយបង្កើតផងដែរ។

អានុភាពដ៏សំខាន់មួយនៃការសុំកូនគឺ ការបញ្ចប់ញាតិភាពរវាងឪពុកម្តាយបង្កើតនឹងកូនសុំព្រមទាំងញាតិលោហិតទាំងអស់របស់ឪពុកមកដាយបង្កើត ប៉ុន្តែប្រសិនបើការបង្កើតសុំកូនពេញលេញនោះជាមួយកូនសហព័ទ្ធម្ខាងទៀតញាត់ភាពរវាងកូនសុំនិងសហព័ទ្ធម្ខាងទៀតដែលជាឪពុកម្តាយបង្កើតរបស់កូននោះព្រមទាំងញាតិលោហិតរបស់គាត់មិនត្រូវបានបញ្ចប់ឡើយ(មាត្រា១០១៤នៃក្រមរដ្ឋប្បវេណី)។

ឧទាហរណ៍ៈរដ្ឋាត្រូវបានឪពុកម្តាយបង្កើតរបស់គាត់យល់ព្រមប្រគល់ទៅអោយលោកពៅ និងលោកស្រីសេដាចិញ្ចឹមមើលថៃជាកូនសុំពេញលេញ។ហេតុដូចនេះហើយក្រោយពីតុលាការបានចេញដីកាសម្រេចបង្កើតសុំកូនពេញលេញនិងបានចូលជាស្ថាពរហើយនោះមានន័យថាឪពុកម្តាយបង្កើត ជីដូនជីតា បងប្អូនរបស់រដ្ឋានឹងមិនត្រូវចាត់ទុកថាជាញាតិដូចកាលពីមុនទៀតទេ។

ព្រមពេលជាមួយគ្នានោះដែរចំណងញាតិភាពរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹមនឹងត្រូវកើតឡើងហើយកូនសុំនឹងទទួលបាននៅឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម នឹងមានសិទ្ធករណីកិច្ចដូចកូនបង្កើតហើយកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ហើយកូនសុំអាចដាក់ត្រកូលខ្លួនពីមុនក៏បានឬចង់ប្តូរមកប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។

ក្រោយពីបំពេញរួចរាល់ហើយចាំបាច់ត្រូវតែធ្វើសំបុត្រកំណើតថ្មីអោយកូនសុំ នៅក្នុងសំបុត្រកំណើតនោះមិនត្រូវសរសេរអំពីសុំកូនទេ នៅពេលដែលកូនសុំក្លាយជាអនីតិជនកូនសុំមានសិទ្ធបង្ហាញនូវព័ត៌មានផ្ទាល់ខ្លួនក្នុងករណីចាំបាច់ក៏ប៉ុន្តែក៏ទាមទារសិទ្ធអាចអនុវត្តន៍បានក្នុងពេលករណីមានគោលបំណងត្រឹមត្រូវនឹងចាំបាច់តែប៉ុណ្ណោះដើម្បីរៀបអាពាហ៍ពិពាហ៍ ព្យាបាលជម្ងឺជាដើម(មាត្រា១០១៨ ១០១៩ នៃក្រមរដ្ឋប្បវេណី)។

## ផ្នែកទី ១ : អានុភាព លើទំនាក់ទំនងញាតិនិងទ្រព្យសម្បត្តិ

### កថាភាគ ទី១ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះកូនស្មុំ

ក្រោយការស្មុំកូន នោះទំនាក់ទំនងឋានៈបុគ្គល ឬហៅថាទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំ(ពីមុនជាកូនបង្កើត) ត្រូវបញ្ចប់ទាំងស្រុង ការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើតនិងកូនសុំត្រូវរលត់តាមផ្លូវច្បាប់[១១]។ បន្ថែមពីនេះទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយបង្កើតជាមួយនឹងកូនក៏ត្រូវរលត់ដូចគ្នាផងដែរ។ ផ្ទុយមកវិញ បើក្នុងករណីដែលសហព័ទ្ធម្ខាងបានសុំកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធដែលត្រូវជាឪពុកបង្កើត ឬម្តាយបង្កើត មិនរលត់ទេ គឺបន្តអត្ថិភាពនៃទំនាក់ទំនងញាតិនេះជាដរាប មានន័យថា កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម នឹងមានសិទ្ធិ និង ករណីយកិច្ចដូចកូនបង្កើត។

នៅពេលកូនស្មុំពេញលេញបានបង្កើតឡើង កូនសុំអាចប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមឬនាមត្រកូលមុនស្មុំកូនបាន។ ក្នុងន័យនេះបញ្ជាក់ថា កូនសុំអាចមានសិទ្ធិក្នុងការប្រើនាមត្រកូលតាមឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនស្មុំកូនបាន។ នេះជាជម្រើសក្នុងការប្រើប្រាស់នាមត្រកូលរបស់កូនសុំអាស្រ័យលើការសម្រេចចិត្ត ។

ក្រៅពីទំនាក់ទំនងស្មុំកូនពេញលេញត្រូវបានបង្កើតតាមរយៈអានុភាពនៃដីកាសម្រេចដែលចូលជាស្ថាពរទំនាក់ទំនងលើទ្រព្យសម្បត្តិរបស់កូនសុំត្រូវបានបង្កើតឡើង។ អាស្រ័យហេតុនេះកូនសុំត្រូវទទួលបានសិទ្ធិធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹមក្នុងឋានៈជាសន្តតិជនលំដាប់ទី១។បន្ថែមពីនេះកូនសុំមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ច។

យោងតាមក្រមរដ្ឋប្បវេណី ដោយបង្កើតស្មុំកូនពេញលេញកូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម នឹងត្រូវទទួលបាននូវសិទ្ធនិងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។

មានន័យថា ទោះបីជាកូនសុំមិនមែនជាកូនបង្កើតរបស់ខ្លួនក៏ដោយ ព្រោះតែអានុភាពនៃការស្មុំកូនពេញលេញគឺត្រូវចាត់ទុកកូនសុំដូចជាកូនមានខាន់ស្លារបស់ខ្លួនផងដែរពោលគឺសិទ្ធនិងករណីកិច្ចរបស់កូនបង្កើតនិងកូនសុំគឺមានដូចគ្នា។ព្រោះថាកូនសុំពេញលេញជាប្រព័ន្ធដែលមានបំណងគ្រប់គ្រងថែរក្សាកូនសុំដោយអោយមានភាព

---

[១១]ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៤

កក់ក្តៅដូចជាកូនបង្កើតនៅក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹមដែរ ដូច្នេះឋានៈរបស់កូនសុំនោះត្រូវធានាអោយបានដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។

**កថាភាគទី២ : អានុភាពនៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្តាយបង្កើត**

ក្រោយសុំកូនបានបង្កើត នោះទំនាក់ទំនងឋានៈបុគ្គល ឬ ហៅថាទំនាក់ញាតិរវាងឪពុកម្តាយបង្កើត និង កូនសុំ ត្រូវបញ្ចប់ទាំងស្រុង។ គោលការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និង កូនត្រូវរលត់តាមផ្លូវច្បាប់។ បន្ថែមពីនេះទៅទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយបង្កើត ជាមួយនឹងកូនសុំក៏ត្រូវរលត់ដូចគ្នាផងដែរ។ ផ្ទុយមកវិញ បើក្នុងករណីដែលសហព័ទ្ធម្ខាងបានសុំកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធដែលត្រូវជាឪពុកបង្កើត ឬ ម្តាយបង្កើតមិនរលត់ទេ គឺបន្តអត្ថិភាពនៃទំនាក់ទំនងញាតិនេះជាដរាប។

តាមច្បាប់សុំកូនពេញលេញ មានភាពខុសគ្នាពីការសុំកូនធម្មតា ព្រោះតម្រូវអោយកាត់ផ្តាច់ទំនាក់ទំនងសាច់ញាតិ និង ញាតិលោហិតជាមួយឪពុកម្តាយបង្កើតរបស់ខ្លួន។ ផ្ទុយទៅវិញគឺជាការបង្កើតនូវទំនាក់ទំនងគតិយុត្តរវាងកូនសុំជាមួយម្តាយឪពុកចិញ្ចឹមទៅវិញ ពោលគឺចាត់ទុកជាកូនបង្កើតរបស់ខ្លួនផងដែរ ទោះបីកូនសុំមិនមែនជាកូនបង្កើតរបស់ខ្លួនក៏ដោយ ។

ការបញ្ចប់ទំនាក់ទំនងឋានៈបុគ្គល ទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្តាយបង្កើត និងកូនត្រូវបានកាត់ផ្តាច់ផងដែរ។ អាស្រ័យហេតុនេះ កូនគ្មានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយបង្កើតហើយ ឪពុកម្តាយបង្កើតក៏លែងមានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់កូនបង្កើតដែរ ពោលគឺឪពុកម្តាយបង្កើត និងកូនលែងក្លាយជាសន្តតិជនទៀតហើយ។ មិនតែប៉ុណ្ណោះចំពោះសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ញាតិលោហិតផ្សេងទៀតរបស់ឪពុកម្តាយបង្កើតក៏ត្រូវរលត់ដែរ។

ដោយហេតុថា របបកូនសុំពេញលេញ គឺធ្វើឡើងក្នុងគោលបំណងចិញ្ចឹមនូវកុមារណាម្នាក់ដែលមានជីវភាពគ្រួសារ ខ្សត់ខ្សោយ ខ្វះលទ្ធភាព យកមកចិញ្ចឹមទុកដូចជាកូនបង្កើតរបស់ខ្លួន អោយបានរស់នៅក្នុងគ្រួសារមួយដែលមានជីវភាពរឹងមាំដែលអាចផ្តល់អនាគតដល់កុមារនោះ។ករណីនេះហើយដែលចាំចាច់អោយកូនសុំ ត្រូវស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ។ បានន័យថា ជាការ បង្ការក្រែងមានការរំខានណាមួយដែលបង្កឡើងដោយឪពុកម្តាយបង្កើតរបស់ កូនសុំដូចជា ការចូលជ្រៀតជ្រែក ការរំខានមិនសមស្របណាមួយ។

ឧទាហរណ៍ ការទាមទាយកកូនទៅវិញ ការទាមទារប្រាក់កាសផ្សេងៗ ការស្នើសុំជួបកូន ឬ ទាមទារអាហារកាតព្វកិច្ចអោយចិញ្ចឹមខ្លួន នៅពេលកូនសុំបានដល់នីតិភាព ឬ ពេញវ័យជាដើម ករណីទាំងអស់នេះត្រូវបានហាមឃាត់ និងរិតត្បិត ពោលគឺមិនអោយធ្វើតាមទំនើងចិត្តឡើង។

**កថាភាគទី៣ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្តាយចិញ្ចឹម**

ផ្ទុយពីឪពុកម្តាយបង្កើត ក្រោយសុំកូនពេញលេញបង្កើតអានុភាព នោះទំនាក់ទំនងឋានៈបុគ្គល ឬ ហៅថាទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំកូនត្រូវបានបង្កើតឡើងតាមការសន្មតរបស់ច្បាប់។ ហើយកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកម្តាយចិញ្ចឹម។ លើសពីនេះទៅទៀត ទំនាក់ទំនងញាតិហើយក្នុងករណីម៉្យាងទៀត កូនសុំក៏លោហិតផ្សេងៗទៀតរបស់ឪពុកម្តាយចិញ្ចឹមជាមួយនឹងកូនក៏ត្រូវបង្កើតឡើងដូចគ្នាផងដែរ។នេះ កូនសុំត្រូវបានទទួលឋានៈ សិទ្ធិ និងករណីកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។អាចផ្លាស់ប្តូរនាមត្រកូលមកដាក់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមបានផងដែរ ហេតុនេះ ឈ្មោះថ្មីរបស់កូនសុំនិង ឪពុកម្តាយចិញ្ចឹមនឹងត្រូវបញ្ចូលក្នុងសំបុត្រកំណើតថ្មីដែលចេញដោយមេឃុំចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋានទៅតាមបែបបទនៃការចុះសំបុត្រកំណើត។

ក្រោយពីសុំកូនត្រូវបានបង្កើត បើទោះបីជាឪពុកម្តាយចិញ្ចឹមលែងលះគ្នា ក៏អានុភាពនៃសុំកូនពេញលេញដែលបានកើតឡើងមិនរលត់ឡើយ ព្រោះថាលក្ខខណ្ឌដែលកំណត់អំពីការសុំកូនដោយសហការគ្នារវាងសហព័ទ្ធ គឺជាលក្ខខណ្ឌសម្រាប់តែបង្កើតសុំកូនពេញលេញតែប៉ុណ្ណោះមិនមែនជាលក្ខខណ្ឌសម្រាប់បន្តទំនាក់ទំនងសុំកូនពេញលេញឡើយ។ ដូចច្នេះហើយ បើកូនសុំនៅជាអនីតិជននៅឡើយកូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបាទោលរបស់ឪពុក ឬ ម្តាយ ណាម្ខាងទៅតាមការពិភាក្សារបស់ឪពុកម្តាយ តាមការសម្រេចរបស់តុលាការ។

បើទំនាក់ទំនងឋានៈបុគ្គលត្រូវបានបង្កើត នោះទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំត្រូវបានបង្កើតជាស្វ័យប្រវត្តិផងដែរ។អាស្រ័យហេតុនេះ កូនសុំមានសិទ្ធិពេញលេញធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹមហើយឪពុកម្តាយចិញ្ចឹមហើយឪពុកម្តាយក៏មានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់កូនសុំដែរ។ពោលគឺឪពុកម្តាយចិញ្ចឹមនិងកូនសុំត្រូវក្លាយជាសន្តតិជនទៅតាមករណីនៃលំដាប់សន្តតិកម្មរៀងៗខ្លួន។ បន្ថែមពីនេះឪពុកម្តាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមក៏មានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីកូនសុំផងដែរ។

## ផ្នែកទី ២ : ការចុះបញ្ជី អត្រានុកូលដ្ឋាន

### កថាភាគទី១ : ការចុះបញ្ជី និងការកែប្រែអត្រានុកូលដ្ឋានកំណើតរបស់កូនសុំ

អានុភាពចម្បងនៃការបង្កើតការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូន និងឪពុកម្តាយចិញ្ចឹម រួមទាំងញាតិរបស់ឪពុកម្តាយចិញ្ចឹម និងកាត់ផ្តាច់ទាំងស្រុង នូវទំនាក់ទំនងរវាងកូន ជាមួយឪពុកម្តាយបង្កើត និងញាតិរបស់ឪពុកម្តាយបង្កើត ។ ការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនត្រូវរលត់តាមផ្លូវច្បាប់។ បន្ថែមពីនេះទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយបង្កើតដូចជា លោកតា និងលោកយាយ ជាអាទិ៍ជាមួយនឹងកូនក៏ត្រូវរលត់ដូចគ្នា ផងដែរ។

ដោយសារតែមូលហេតុនេះ ឪពុកម្តាយចិញ្ចឹម ត្រូវធ្វើការកែប្រែបញ្ជីកំណើតរបស់កូនសុំជាថ្មី ដោយភ្ជាប់ទៅជាមួយនឹងដីកាសម្រេចបង្កើតសុំកូនរបស់តុលាការ [១២]។ ថ្វីត្បិតតែក្រមរដ្ឋប្បវេណី ពុំបានបញ្ញត្តិអំពីនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានរបស់កូនសុំ ក្រោយដីកាសម្រេចបង្កើតសុំកូនពេញលេញចូលជាស្ថាពរក៏ដោយ ក៏នៅមានលិខិតបទដ្ឋានដទៃទៀតបានកំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលម្អិតនៅក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានដែរ។ ក្នុងនោះដីកាសម្រេចបង្កើតសុំកូនពេញលេញ នឹងក្លាយជាមូលដ្ឋានគតិយុត្តយ៉ាងសំខាន់សម្រាប់កូនសុំ និងឪពុកម្តាយចិញ្ចឹមក្នុងការរៀបចំ និងកែប្រែអត្រានុកូលដ្ឋានកំណើតថ្មី ដូចជា ការធ្វើសំបុត្រកំណើតថ្មី និងសៀវភៅគ្រួសារថ្មីជាអាទិ៍។ពេលបង្កើតសុំកូនហើយ កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនក៏បាន។ ឪពុកម្តាយចិញ្ចឹមដែលបានសុំកូន ត្រូវទៅចុះបញ្ជីកំណើតថ្មីឲ្យកូនសុំនោះ ដែលបញ្ជីកំណើតថ្មី ត្រូវយកលេខចុះបញ្ជីពីសំបុត្រកំណើតចាស់របស់ក្មេង ដោយអាចធ្វើការផ្លាស់ប្តូរឈ្មោះ និងនាមត្រកូល របស់កូនសុំ និងឈ្មោះឪពុកម្តាយចិញ្ចឹម តែមិនត្រូវសរសេរចូលពីអំពីការសុំកូនឡើយ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាសំបុត្រកំណើតចាស់ ដោយបិទស្រោមសំបុត្រទុកតម្កល់ជាឯកសារនៅការិយាល័យរបស់ខ្លួន។សំបុត្រកំណើតថ្មីរបស់កូនសុំ ត្រូវបញ្ចូលឈ្មោះឪពុកម្តាយចិញ្ចឹមក្នុងសំបុត្រកំណើតថ្មីដែលចេញឲ្យដោយមន្ត្រីអត្រានុកូលដ្ឋាន គឺ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានរបស់ឪពុកម្តាយចិញ្ចឹម។

### កថាភាគទី២ : ការរក្សាការសម្ងាត់អត្រានុកូលដ្ឋានកំណើតរបស់កូនសុំ

ព័ត៌មានដែលទាក់ទងនឹងការសុំកូនពេញលេញ គឺជាការសម្ងាត់ នៅក្នុងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ [១៣]។ ការធ្វើដូច្នេះ គឺ

---

[១២] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៨

[១៣] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៨

ការសម្ងាត់ពីការខ្ចីនេះ ព្រោះពុំចង់ឲ្យមានហានិភ័យ ដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្តាយបង្កើត ដែលធ្វើឲ្យស្ថានភាពគ្រួសារកូនសុំ មានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវបរិស្ថានរីកចម្រើនលូតលាស់ដែលមានលំនឹងសម្រាប់កុមារ។ បញ្ជីអត្រានុកូលដ្ឋាន និងសំបុត្រកំណើតថ្មី របស់កូនសុំ ដែលធ្វើឡើងដោយការបង្កើតសុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះរបស់ឪពុកម្តាយបង្កើត ឬចំណុចស្តីពីសុំកូនឡើយ ហើយត្រូវចុះថាឪពុកម្តាយចិញ្ចឹម គឺជាឪពុកម្តាយបង្កើត។

ការបង្កើតសុំកូនពេញលេញបញ្ជីកំណើតរបស់កូនសុំត្រូវតែធ្វើសាជាថ្មី ប៉ុន្តែនៅក្នុងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬឯកសារដកស្រង់នៃបញ្ជីកំណើតមិនត្រូវសរសេរអំពីចំណុចសុំកូនឡើយ។

បញ្ជីអាត្រានុកូលដ្ឋាននិងសំបុត្រកំណើតថ្មីរបស់សុំកូនដែលធ្វើឡើងដោយការងង្កើតសុំកូនពេញលេញមិនត្រូវសរសេរឈ្មោះឪពុកម្តាយបង្កើត ចំណុចស្តីពីសុំកូនឡើយហើយត្រូវចុះថាឪពុកម្តាយចិញ្ចឹមគឺជាឪពុកម្តាយបង្កើត។

នៅក្នុងករណីសុំកូនពេញលេញជាការសង្គ្រោះចំពោះកុមារអភ័ព្វដែលជាការបង្ហាញនូវអង្គហេតុនៃការសុំកូននេះអាចបំពានភាពឯកជននឹងបានផ្តល់ភាពអាក្រក់ទៅដល់ការរីកចម្រើនលូតលាស់ដ៏ល្អរបស់កុមារ ម្យ៉ាងវិញទៀតការបង្ហាញបែបនេះក៏អាចនាំអោយមានហានិភ័យដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្តាយបង្កើត ដែលធ្វើអោយស្ថានភាពគ្រួសារកូនសុំអាចមានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវភាពរីកចម្រើនលូតលាស់ដែលមានលំនឹងសម្រាប់កុមារ។

កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ឬនាមត្រកូលមុនសុំកូនក៏បានដែរ។បែបបទនិងនីតិវិធីស្នើសុំសំបុត្រកំណើតថ្មីអនុវត្តតាមអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន។ នៅពេលដែលកូនសុំ ក្លាយជានីតិជនកូនសុំអាចទាមទារឱ្យបង្ហាញនូវព័ត៌មានផ្ទាល់ខ្លួនទាក់ទងក្នុងទំហំដែលចាំបាច់ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងក្តីទាក់ទងនឹងសុំកូននោះ។ ក៏ប៉ុន្តែសិទ្ធិទាមទារនេះ អាចអនុវត្តបានចំពោះករណីដែលមានគោលបំណងត្រឹមត្រូវតែប៉ុណ្ណោះមានជាអាទិ៍ករណីចាំបាច់ដើម្បីព្យាបាលជំងឺឬដើម្បីរៀបអាពាហ៍ពិពាហ៍។

## ផ្នែកទី៣ : សិទ្ធិដឹងអំពីកំណើតខ្លួន

ប្រសិនបើមានការយល់ព្រមពីឪពុកម្តាយបង្កើតត្រូវមានឯកសារជាលាយល័ក្ខណ៍អក្សរ និងមានពាក្យសុំរបស់កូនសុំដែលមានអាយុលើសពី២១ឆ្នាំហើយស្ថាប័នសម្របសម្រួលសុំកូនឬមន្ទីរសង្គមកិច្ចស្រុកអាចបង្ហាញថានូវឈ្មោះ និងអាស័យដ្ឋានរបស់ឪពុកម្តាយបង្កើតដល់កូនសុំបាន ហើយប្រសិនបើមានការយល់ព្រមពីកូនសុំដែលបាននីតិភាព ស្ថាប័នសម្របសម្រួលសុំកូន ឬមន្ទីរសង្គមកិច្ចស្រុកក៏អាចបង្ហាញនូវឈ្មោះ នឹងអាស័យដ្ឋានរបស់កូនសុំដល់កូនសុំដល់ឪពុកម្តាយបង្កើតបានដែរ( មាត្រា៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា )យើងតាមកថាខណ្ឌទី១ មាត្រា៧នៃអនុសញ្ញាស្តីពីសិទ្ធកុមារ បានទទួលស្គាល់សិទ្ធិដឹងអំពីប្រភពកំណើតរបស់កុមារ មាន

ន័យថាបញ្ហាប្រឈមនៅពេលខាងមុខគឺជាការថ្លឹងថ្លែងរវាងសិទ្ធិរបស់ឪពុកម្តាយបង្កើតដែលមិនចង់អោយស្គាល់ ឬការទាមទារការរក្សាការសម្ងាត់ជាមួយសិទ្ធិរបស់កុមារក្នុងការដេងអំពីអត្តសញ្ញាណរបស់ខ្លួន។

**កថាភាគទី១ : ការដាក់ពាក្យសុំទៅតុលាការ**

តាមមាត្រានេះយើងអាចសន្និដ្ឋានថាទម្រង់នៃការសុំកូនពេលលេញមិនអាចធ្វើឡើងដោយផ្ទាល់មាត់បានទេ ពោលគឺធ្វើឡើងជាលាយលក្ខណ៍អក្សរព្រោះការសុំកូនពេញលេញអាចប្រព្រឹត្តទៅបានលុះត្រាតែមានសេចក្តីសម្រេចពីតុលាការហើយសេចក្តីសម្រេចនេះអាចធ្វើទៅបានតុលាការនឹងពិចារណាទៅលើការពិបាកយ៉ាងខ្លាំងផ្នែកជីវភាពឬមិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំដោយឪពុកម្តាយបង្កើតឬមានស្ថានភាពពិសេសផ្សេងទៀត ប្រសិនបើមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ។ពោលគឺស្ថិតនៅក្រោមលក្ខខណ្ឌយ៉ាងតឹងរឹងមួយដោយតម្រូវអោយមានសេចក្តីសម្រេចពីតុលាការ។ករណីនេះមានភាពផ្សេងគ្នានៃការសុំកូនធម្មតាតាមទម្រង់កិច្ចសន្យាកើតឡើងតាមការព្រមព្រៀងសុំកូននិងការដាក់ពាក្យសុំចុះបញ្ជីសុំកូន។សុំកូនតាមទម្រង់កិច្ចសន្យាជាករណីដែលភាគច្រើននៃទំនាក់ទំនងត្រូវបានចងដោយពិចារណាទៅលើស្ថានភាពមនុស្សពេញលេញវ័យសម្រាប់ការសុំកូនពេញលេញនេះកំណត់យកអនីតិជនដែលមានស្ថានភាពគ្រួសារមិនអំណោយផលអ្វីជាកម្មវត្ថុដោយតម្រូវអោយមានការស្រាវជ្រាវនិងវិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍កុមារជាចម្បងដោយសុំកូនប្រភេទនេះមានគោលបំណងបង្កើតឡើងទំនាក់ទំនងជាមួយដែលដូចគ្នានិងទំនាក់ទំនងនៃឪពុកម្តាយនិងកូនបង្កើតដូច្នេះដែរ(សេចក្តីកំណត់មាត្រានីមួយនៃក្រមរដ្ឋប្បវេណីមាត្រា១០០៧)។នៅក្នុងន័យនេះសិទ្ធនិងកាតព្វកិច្ចរបស់កូនសុំគឺដូចគ្នានិងកូនមានខាន់ស្លារបស់ខ្លួនដែរ។ដូចនេះបានជាការសុំកូនពេញលេញត្រូវបំពេញលក្ខខណ្ឌទម្រង់មានសេចក្តីសម្រេចរបស់តុលាការទើបទទួលបានអានុភាពគតិយុត្តិ។

សុំកូនពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឲ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ។ ចំពោះការរក្សាទុកសំណុំរឿង និងវិធីទាមទារឲ្យបង្ហាញជាអាទិ៍ ត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិរបស់តុលាការ [១៤]។

---

១៣ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៨

១៤ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០១៩

## កថាភាគទី២ : ការជួបប្រាស្រ័យជាមួយឪពុកម្តាយបង្កើតនិងបងប្អូនញាតិលោហិត

នៅក្នុងប្រទេសមួយចំនួន ការអនុញ្ញាតិឲ្យកូនសុំ បានស្គាល់គ្នាជាមួយឪពុកម្តាយបង្កើត បងប្អូនបង្កើតឬញាតិខាងឪពុកម្តាយបង្កើត ត្រូវបានគេបើកទូលាយ ពេលដែលកូនសុំមានអាយុ ដល់វ័យនីតិភាព។ ក្រៅពីនេះក៏មានប្រព័ន្ធរៀបចំឲ្យមានការជួបមុខផ្ទាល់រវាងកូនសុំដែលដល់នីតិជន និងឪពុកម្តាយបង្កើត បងប្អូនបង្កើត ឬញាតិខាងឪពុកម្តាយបង្កើតផងដែរ ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីគ្រួសាររបស់កូនសុំ។

ក្រោយបង្កើតសុំកូនញាតិជាមួយឪពុកម្តាយបង្កើតត្រូវបានបញ្ចប់មានន័យថាឪពុកម្តាយនិងកូនបង្កើតក្លាយជាអ្នកដទៃលែងជាប់សាច់ញាតិ សាច់ឈាមជាមួយគ្នាហើយញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវបញ្ចប់ដែរ។លើកលែងតែករណីកូនសុំជាកូនរបស់សហព័ទ្ធម្ខាងទៀត

នៅប្រទេសមួយចំនួនមានការអនុញ្ញាតអោយកូនសុំបានស្គាល់គ្នាជាមួយនឹងឪពុកម្តាយបង្កើតបងប្អូនបង្កើតឬញាតិលោហិតខាងឪពុកម្តាយបង្កើតត្រូវបានគេបើកទូលាយពេលដែលកូនសុំមានអាយុដល់វ័យនីតិភាព ក្រៅពីនេះប្រព័ន្ធក៏មានការរៀបចំអោយមានការជួបមុខគ្នាផ្ទាល់រវាងកូនសុំ និងឪពុកម្តាយបង្កើយ បងប្អូនបង្កើតផងដែរប្រសិនបើមានការយល់ព្រមពីឪពុកម្តាយចិញ្ចឹមជាលាយល័ក្ខអក្សរ

ហេតុដូចនេះសិទ្ធធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមកត្រូវបានបាត់បង់នឹងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមកបានទៀតទេហើយឪពុកម្តាយបង្កើតក៏ពុំមានសិទ្ធសួរសុខទុក្ខកូនដែរ។

ការកំណត់បែបនេះមានគោលបំណងនៃការបង្កើតសុំកូនពេញលេញគឺបង្កើតញាត់ភាពថ្មីមួយនៅក្នុងមជ្ឈដ្ឋាននៃគ្រួសាររបស់ឪពុកម្តាយចិញ្ចឹមហេតុនេះដើម្បីជៀសវាងការការរំខានទៅដល់សេចក្តីសុខ ឬជ្រៀតជ្រែកដោយមិនសមរម្យពីឪពុកម្តាយបង្កើតហើយត្រូវតែបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។

# ជំពូកទី ៣
# ការកាត់កាលក្លូនស៊ាំពេញលេញ

# ជំពូកទី ៣

# ការកាត់កាលកូនសុំពេញលេញ

ក្នុងក្រមរដ្ឋប្បវេណីមិនបានអោយនិយមន័យនៃការកាត់កាលនោះទេតែបើក្រលេកមើលវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជជួនណាតបានកំណត់ថាកាត់កាល(កិ.)បោះបង់លែងរាប់អានតទៅ។ដូចនេះការកាត់កាលសុំកូនពេញលេញជាស្ថានភាពមួយដែលបញ្ចប់ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចញ្ចឹម។

ការកាត់កាលសុំកូនពេញលេញ គឺ ជាការបញ្ចប់ទំនាក់ទំនងរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម និង ទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម បូករួមទាំងការផ្តាច់ទំនាក់ទំនង សិទ្ធ និងកាតព្វកិច្ច ដូចជា អាហារកាតព្វកិច្ច និង សន្តតិកម្ម ។

## ផ្នែកទី១ : មូលហេតុ នៃការកាត់កាល

យើងដឹងហើយថា ការសុំកូនពេញលេញ គឺធ្វើឡើងក្នុងគោលបំណងដើម្បីផលប្រយោជន៍របស់កុមារ ដែលរស់នៅក្នុងស្ថានភាពគ្រួសារ ដែលបានជួបប្រទះនូវការលំបាកផ្នែកសេចដ្ឋកិច្ច។ ប៉ុន្តែករណីនេះពេលខ្លះ ក៏មិនអាចប្រព្រឹត្តទៅបានទាំងអស់ដែល ព្រោះករណីខ្លះមានមូលហេតុមួយចំនួន ដែលអាចឈានដល់ការកាត់កាលកូនសុំពេញលេញបាន ប្រសិនបើមានមូលហេតុដូចដែកបានកំណត់ក្នុងមាត្រា១០១៦ នៃ ក្រមរដ្ឋប្បវេណី ដោយបានបញ្ញត្តិថា បើមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូន តុលាការអាចកាត់កាលភាគីនៃសុំកូនបានតាមពាក្យសុំរបស់ឪពុកម្តាយបង្កើត ឬ ក៏តំណាងអយ្យការ។

សុំកូនពេញលេញមានបំណងផ្តល់នូវការគ្រប់គ្រងថែរក្សាដូចជាកូនបង្កើតដូច្នេះការកាត់កាលនេះមិនត្រូវទទួលស្គាល់ឡើយប៉ុន្តែក្នុងករណីដែលការទំនាក់ទំនងសុំកូនធ្វើអោយប៉ះពាល់ធ្ងនព្ធធ្ងរដល់ប្រយោជន៍កុមារ ឬករណីដែលអាចពឹងបាននូវការគ្រប់គ្រងថែរក្សាដោយគ្រប់គ្រាន់ដោយឪពុកម្តាយបង្កើតជាករណីលើកលែងបញ្ញត្តិទទួលស្គាល់ការរំលាយសុំកូនបាន។ យោងតាមមាត្រា១៣ កថាខណ្ឌ១ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុបកំណត់ថាក្នុងអឡុងពេលកូនសុំមិនទាន់ដល់នីរភាពសុំកូនអាចត្រូវបានលុបចោលបានតាមការសម្រេចរបស់អាជ្ញារធរតុលាការឬអាជ្ញាធររដ្ឋបាល ប៉ុន្តែនៅក្នុងករណីដែលមូលហេតុធ្ងន់ធ្ងរប៉ុណ្ណោះ។

**ឧទាហរណ៍**:បន្ទាប់ពីសុំកូនបានរួចរាល់ហើយ កូនសុំបានរស់នៅជាមួយឪពុកម្តាយចិញ្ចឹម ប្រសិនបើក្នុងអំឡុងពេលរស់នៅមួយរយះជាមួយឪពុកម្តាយចិញ្ចឹម កូនសុំបានទទួលរងនៅការធ្វើបាបឥតល្ហែពីឪពុកម្តាយចិញ្ចឹម។ជាងនេះទៅទៀតឪពុកម្តាយបង្កើតរបស់កូនសុំដែលធ្លាប់មានជីវភាពលំបាក ឬមានជំងឺពីមុនគាត់អាចមានភាពធូរស្រាលនឹងអាចប្រកបរបររកស៊ី ឬជំនួញឡើងវិញធ្វើអោយជីវភាពមានភាពធូរជារល្អប្រសើរជាងមុន។ នៅក្នុងករណីនេះឪពុកម្តាយបង្កើតមានបំណងចង់ទាមទារកូនមកវិញត្រូវដាក់ពាក្យបណ្តឹងទាមទាតកាត់កាល បើ

តុលាការយល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីលក្ខខណ្ឌនៃការកាត់កាលដូចខាងលើនេះ តុលាការនឹងសម្រេចចិត្តចេញសាលក្រមដើម្បីប្រកាសពីការកាត់កាលសុំកូនពេញលេញ។

**កថាភាគទី១ : ការបំពានផលប្រយោជន៍**

បើមានការធ្វើបាប ដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬមូលហេតុផ្សេងៗទៀតដែលបំពានលើផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។ ការធ្វើបាបដោយសកម្មភាពផ្សេងៗ វាយដំ ធ្វើទារុណកម្មដែលបណ្តាលអោយកូនសុំរងទុក្ខទាំងផ្លូវកាយ និងផ្លូវចិត្តពីសំណាក់ឪពុកម្តាយចិញ្ចឹម ឬ បោះបង់កូនសុំចោលដោយមិនបំពេញតួនាទីជាអ្នកមានសិទ្ធិអំណាចជាមេបាលើកូនសុំនោះ ។ ករណីនេះគឺប្រព្រឹត្តផ្ទុយពីគោលបំណងនៃការសុំកូន ព្រោះការសុំកូនកើតចេញពីអនុគ្រោះលើកុមារដែលខ្វះខាតខាងជីវភាព កាលដែលមិនអាចបំពេញករណីយកិច្ចដើម្បីធ្វើជាប្រយោជន៍ដល់កូនសុំទេ តុលាការអាចកាត់កាលភាគីសុំកូនបាន តាមពាក្យស្នើសុំរបស់ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងស្នើសុំកាត់កាល់កូនសុំព្រោះមូលហេតុដូចបានបញ្ជាក់នេះ ។

**កថាភាគទី២ : លទ្ធភាពម្តាយឪពុកបង្កើត**

បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថៃរក្សាដោយសមរម្យ។ដូចបានបកស្រាយខាងលើការបង្កើតអោយមានការសុំកូនធ្វើឡើងដោយផ្តោតសំខាន់ទៅលើផលប្រយោជន៍របស់កូនសុំនោះដោយសារស្ថានភាពគ្រួសារទន់ខ្សោយ។ផ្ទុយទៅវិញប្រសិនបើស្ថានភាពគ្រួសាររបស់ឪពុកម្តាយបង្កើតមានជីវភាពធូរជារមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទំនុកបម្រុងចិញ្ចឹមបីបាច់ថែរក្សាពោលគឺអាចគ្រប់គ្រងកូនអោយល្អប្រសើរនោះមូលហេតុនេះច្បាប់បានអនុញ្ញាតអោយស្នើរសុំកាត់កាលកូនសុំពេញលេញបាន។ហើយអ្នកដែលមានសិទ្ធគឺកូនឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ។

សរុបមកយើងឃើញថាការសុំកូនពេញលេញគឺមានបំណងផ្តល់ការគ្រប់គ្រងថៃរក្សាដោយចាត់ទុកដូចជាកូនបង្កើតរបស់ខ្លួនដែរ។ដូចនេះករណីធម្មតាការកាត់កាលមិនត្រូវបានទទួលស្គាល់ឡើយ។ប៉ុន្តែករណីដែលការបន្តទំនាក់ទំនងសុំកូនធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរដល់ប្រយោជន៍កុមារឬករណីដែលអាចពឹងបានអំពីការគ្រប់គ្រងថៃរក្សាគ្រប់គ្រងដោយឪពុកម្តាយបង្កើតវានឹងមានអនុភាពតាមផ្លូវច្បាប់ដើម្បីដាក់ពាក្យរំលាយទំនាក់ទំនងគតិយុត្តរវាងកូនសុំនិងឪពុមម្តាយចិញ្ចឹមតាមនីតិវិធីរបស់តុលាការប្រសិនបើមានមូលហេតុដូចបានបញ្ជាក់ជូននេះ។

សូមបញ្ជាក់ថាដើម្បីអាចកាត់កាលកូនសុំពេញលេញបានលុះត្រាតែមានលក្ខខណ្ឌដូចបកស្រាយខាងលើទោះបីមូលហេតុណាមួយក៏ដោយ។ផ្ទុយទៅវិញបើគ្មានលក្ខខណ្ឌដូចបានកំណត់នេះទេ ការកាត់កាលកូនសុំពេញលេញក៏មិនអាចនឹងប្រព្រឹតហតទៅបានទេ( មាត្រា១០១៦ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណី )។

## ផ្នែកទី ២ : អ្នកមានសិទ្ធប្តឹងកាត់កាល

ការកាត់កាលសុំកូនពេញលេញ មិនមែនសុទ្ធតែអាចធ្វើឡើងដោយបុគ្គលគ្រប់រូបនាបឡើយ ព្រោះការ កាត់កាល នាំអោយមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កុមារដែលជាកូនសុំ ដូច្នេះហើយបានជាច្បាប់បានបញ្ញត្តិយ៉ាងច្បាស់ពីអ្នកដែលងាចមានសិទ្ធិ ដាក់ពាក្យបណ្តឹងសុំកាត់កាលសុំកូននេះបាន បុគ្គលដែលមានសិទ្ធិនោះ ត្រូវជាអ្នកដែលបានគិតគូរយ៉ាងល្អិតល្អន់ពីផលប្រយោជន៍របស់កូនសុំ និង ជាអ្នកដែលមានទំនាក់ទំនង ការពារ សិទ្ធិរបស់កូនសុំ ។

ហើយការកាត់កាលនេះអាចធ្វើបានលុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុច ទាំងអស់ដែល បានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមៈ

### កថាភាគទី១ : តំណាងអយ្យការ

តុលាការជាអ្នកមានអំណាចសម្រេចលើការកាត់កាលភាគីនៃកូនសុំបានបើយល់ឃើញថាការកាត់កាលមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់ កូនសុំតាមពាក្យរបស់កូនសុំឪពុកម្តាយបង្កើត ឬតំណាងអយ្យការ។

### កថាភាគទី២ : ម្តាយឪពុកបង្កើត

បើមាការធ្វើបាបដោយឪពុកម្តាយចញ្ចឹមបោះបង់កូនចោលដោយគំនិតទុច្ចរិតឬហេតុផលផ្សេងៗដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរហើយឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

### កថាភាគទី៣ : កូនសុំ

នៅក្នុងច្បាប់អាពាហ៍ពិពាហនិងគ្រួសារក៏បានកំណត់[១៥]ថាតុលាការប្រជាជនអាចបដិសេធកិច្ចសន្យាសុំកូនបានតាមពាក្យបណ្តឹងរបស់កូនចញ្ចឹមរបស់ជនទាំងឡាយឬអង្គការផ្សេងៗទៀតដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹម។

បញ្ញាតិដែលបានចែងនៅក្នុងច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារឃើញថាមានភាពទូលំទូលាយជាងដែលបើកទូលាយចំពោះអោយជនទាំងឡាយនិងអង្គការផ្សេងៗដាក់ពាក្យបណ្តឹងដើម្បីបដិសេធសុំកូននេះដែលអាចបន្ថែមការការពារដល់ប្រយោជន៍របស់កូនសុំមួយកំរិតថែមទៀត។

---

[១៥]ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា៩៩១

## ផ្នែកទី ៣ : អានុភាពនៃការកាត់កាល

នៅពេលដែលការសុំកូនពេញលេញត្រូវបានរលត់ ដោយសាលក្រមរបស់តុលាការ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបានបញ្ចប់ រីឯញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ នឹងត្រូវបានបង្កើតឡើងវិញ គិតចាបពីថ្ងៃកាត់កាល់។

អានុភាពនៃការកាត់កាលសុំកូន បាននាំឲ្យមានទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកបង្កើត និង ម្តាយបង្កើតត្រូវតភ្ជាប់ឡើងវិញដោយស្វ័យប្រវត្តិ គឺបានន័យថា នៅពេលដែលសាលក្រមបានចូលជាស្ថាពរ[១៦] អ្វីៗនឹងត្រលប់ទៅជាសភាពដើមវិញ ដូចមុនពេលដែលការសុំកូនពេញលេញត្រូវបានបង្កើត ដែលបានរៀបរាប់ដូចខាងក្រោម។

គួរកត់សម្គាល់ ៖

➢ តើអានុភាពនៃការកាត់កាលសុំកូន មានអានុភាពប្រតិសកម្មដែរឬទេ? ហើយវាមានអានុភាពដូចម្តេច

ចំពោះឪពុកម្តាយចិញ្ចឹម , កូនសុំ និងឪពុកម្តាយបង្កើត?

មាត្រានេះបានអនុម័តនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំនឹងឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើតដែលត្រូវបានបញ្ចកចប់ដោយការបង្កើតសុំកូននៅពេលដែលសុំកូនពេញលេញត្រូវបានរំលាយដោយការកាត់កាល ។

នៅក្នុងការទទួលស្គាល់ការកាត់កាលនៅមានការខ្វែងគំនិតគ្នាលើចំណិចថាតើញាតិភាពជាមួយឪពុកម្តាយបង្កើត និងគ្រួសារបង្កើតដែលបានបញ្ចប់ដោយការបង្កើតសុំកូនត្រូវបានបង្កើតវិញដោយស្វ័យប្រវត្តិឬ យ៉ាងណា។

### កថាភាគទី១ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះកូនសុំ

- អានុភាពទៅលើឋានៈបុគ្គល

នៅពេលសុំកូនពេញលេញបានរំលាយ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត និងញាតិភាពជាមួយ

[១៦] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសអោយប្រើថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា១០៣៧

ញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវបានកើតឡើងវិញដោយស្វ័យប្រវត្តិ កូនសុំត្រូវស្ថិតក្រោមរបប អំណាចមេបារបស់ឪពុកម្តាយបង្កើត ។ ដោយក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំបានចែងពីការប្រើប្រាស់នាមត្រកូលរបស់កូនសុំឡើយ ថាអាចបន្តប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬត្រូវប្តូរទៅនាមត្រកូល មុនពេលបង្កើតសុំកូនពេញលេញវិញឬយ៉ាងទេ។ ដោយឡែកតាមបញ្ញត្តិនៃសុំកូនធម្មតា បានកំណត់យ៉ាងច្បាស់ថា ក្រោយកាត់កាល សុំកូនធម្មតា កូនសុំអាចបន្តប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬត្រូវប្តូរទៅនាមត្រកូល មុនពេលបង្កើតសុំកូនវិញក៏បាន។ប៉ុន្តែបើកូនសុំ នៅបន្តប្រើនាមត្រកូលឪពុកម្តាយចិញ្ចឹម នោះសំបុត្រកំណើតថ្មីរបស់កូនសុំ និងត្រូវចុះបញ្ជី ដោយយកឪពុកម្តាយបង្កើត ដាក់បញ្ចូលក្នុងសំបុត្រកំណើតថ្មីវិញហើយ មេឃុំ ឬ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាននឹងបំពេញបែបបទនៃការចុះសំបុត្រកំណើត។

- អានុភាពទៅលើទព្យសម្បត្តិ

ក្រៅពីទំនាក់ទំនងសុំកូនពេញលេញ ត្រូវបានបញ្ចប់តាមរយៈអានុភាពនៃសាលក្រមចូលជាស្ថាពរទំនាក់ទំនងលើទ្រព្យសម្បត្តិរបស់កូនសុំ ត្រូវបានបង្កើតឡើងវិញ ជាមួយឪពុកម្តាយបង្កើត រួមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតផងដែរ។

បន្ថែមពីនេះ កូនសុំមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ច និងទទួលបាន សិទ្ធិធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយបង្កើត ក្នុងឋានៈជាសន្តតិជនលំដាប់ទី១ រីឯឪពុកម្តាយបង្កើតនិងញាតិរបស់ឪពុកម្តាយបង្កើត ក៏មិនអាចធ្វើសន្តតិកម្មលើមត៌ករបស់កូនវិញបានដូចគ្នា។

**កថាភាគទី២ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្តាយបង្កើត**

- អានុភាពទៅលើឋានៈបុគ្គល

ដោយសារតែការសុំកូនពេញលេញ ត្រូវបានបញ្ចប់ដោយសាលក្រមរបស់តុលាការ អានុភាពនៃញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវបានកើតឡើងវិញដោយស្វ័យប្រវត្តិ គិតចាប់ពីថ្ងៃកាត់កាល់នោះ។ ម្យ៉ាងទៀតកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបា របស់ឪពុកម្តាយបង្កើតវិញ។ បន្ថែមពីនេះទៀត កូនសុំក៏អាចផ្លាស់ប្តូរនាមត្រកូល មកដាក់នាមត្រកូល របស់ឪពុកម្តាយបង្កើតបានផងដែរ ហេតុនេះហើយសំបុត្រកំណើតចាស់របស់កូនសុំ ដែលបានរក្សាទុកដោយមន្ត្រីអត្រានុកូលដ្ឋានមុនបង្កើតសុំកូន អាចត្រូវបានយកមកប្រើប្រាស់វិញ។

- អានុភាពទៅលើទព្យសម្បត្តិ

ផ្សេងពីការបង្កើតទំនាក់ទំនងឋានៈបុគ្គល ទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្ដាយបង្កើត និងកូននឹងត្រូវបានតភ្ជាប់វិញផងដែរ ព្រមទាំងសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ញាតិលោហិតផ្សេងទៀតរបស់ឪពុកម្ដាយបង្កើត ពោលគឺឪពុកម្ដាយបង្កើត និងកូន ក្លាយជាសន្តតិជនម្ដងទៀត។

**កថាភាគទី៣ : អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិចំពោះ ឪពុកម្ដាយចិញ្ចឹម**

- អានុភាពទៅលើឋានៈបុគ្គល

ក្រោយពីសុំកូនពេញលេញ បានរំលាយហើយនោះ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម ក៏ដូចជាញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ទាំងស្រុង គឺមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្ដាយចិញ្ចឹម និងកូនត្រូវរលត់តាមផ្លូវច្បាប់ បន្ថែមពីនេះទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្ដាយចិញ្ចឹម ជាមួយនឹងកូនសុំ ក៏ត្រូវរលត់ដូចគ្នាផងដែរ ហើយកូនសុំត្រូវមិនស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកម្ដាយចិញ្ចឹមទៀតនោះទេ។

- អានុភាពទៅលើទព្យសម្បត្តិ

ក្រៅពីអានុភាពលើទំនាក់ទំនងញាតិភាព អានុភាពលើទ្រព្យសម្បត្តិ ក៏មានអានុភាពកើតឡើងដែរមានន័យថា កូនសុំ លែងជាបុគ្គលដែលមានសិទ្ធិក្នុងការបន្តសន្តិតិកម្មលើទ្រព្យសម្បត្តិ របស់ឪពុកម្ដាយចិញ្ចឹមនិងញាតិរបស់ឪពុកម្ដាយចិញ្ចឹមទៀតហើយ ចំណែកឯឪពុកម្ដាយចិញ្ចឹម និងញាតិរបស់ឪពុកម្ដាយចិញ្ចឹម ក៏មិនអាចធ្វើសន្តតិកម្មលើមត៌ករបស់កូនសុំវិញបានដូចគ្នា។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវបកស្រាយប្រធានបទខាងលើនេះរួចមកនាងខ្ញុំយល់ឃើញថា ប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមជាតិទាំងមូល ហើយបានធ្វើអោយខ្ញុំយល់ដឹងកាន់តែច្បាស់ថាការបង្កើតច្បាប់ទាក់ទងនឹងការសុំកូននេះមកបានជួយការការពារទៅដល់កុមាររងគ្រោះជាច្រើនដែលកំពុងពិបាក ហើយក៏បានជួយទៅដល់គ្រួសារដែលពិបាកនៅក្នុងការមានកូន ឬពុំអាចមានកូនបានធ្វើអោយមានគ្រួសារមួយទទួលក្ដីសុខនឹង មានសុភមង្គលពេញលេញបរិបូរណ៍ផងដែរ។

មុនពេលដែលមិនទាន់ជ្រើសរើសប្រធានបទនេះមកធ្វើការស្វែងយល់បន្ថែមនោះនាងខ្ញុំគ្រាន់តែយល់ថាការបង្កើតសុំកូនពេញលេញក៏បានធ្វើអោយប្រជាពលរដ្ឋដឹងអំពីការវិនិច្ឆ័យរបស់តុលាការទាក់ទងនឹងសុំកូននេះថាតើមូលហេតុ ឬស្ថានភាពបែបណាដែលអាចឱ្យឪពុកម្ដាយចិញ្ចឹមសុំកូនមកចិញ្ចឹមបាន ។ កាលណាដែលសុំបានមកគឺយើងក៏បានដឹងពីអានុភាពនៃសុំកូនពេញលេញហើយក៏បានដឹងអំពីការកាត់កាល់និងអានុភាពនៃការកាត់កាល់ផងដែរ ។

នៅក្នុងប្រភេទនៃសុំកូនហើយដឹងអំពីលក្ខខណ្ឌនៃការសុំដែលមានទាក់ទងនឹងលក្ខខណ្ឌអាយុរបស់ឪពុកម្ដាយ លក្ខខណ្ឌអាយុរបស់កូន។ មួយវិញទៀតគឺបានដឹងអំពីករណីណា ឬស្ថានភាពណាដែលអាចសុំកូនបានពីឪពុកម្ដាយបង្កើតដូចជាឪពុកម្ដាយពិបាកយ៉ាងខ្លាំងក្នុងការចិញ្ចឹម និង ជីវភាពលំបាក មូលហេតុផ្សេងៗទៀតដែលចាំបាច់ហើយដើម្បីផលប្រយោជន៍កុមារទើបនាំឱ្យមានការសុំកូនបាន។នៅក្នុងនេះដែរក៏បានដឹងអំពីការវិនិច្ឆ័យរបស់តុលាការទាក់ទងនឹងសុំកូននេះថាតើមូលហេតុឬស្ថានភាពបែបណាដែលអាចឱ្យឪពុកម្ដាយចិញ្ចឹមសុំកូនមកចិញ្ចឹមបានម្យ៉ាងវិញទៀតការបង្កើតសុំកូនពេញលេញគឺធ្វើឱ្យទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹមដូចជាញាតិនៃឪពុកម្ដាយបង្កើតផងដែរហើយអាចធ្វើឱ្យកុមារអភ័ព្វបានរួមរស់នៅជាមួយឪពុកម្ដាយចិញ្ចឹមយ៉ាងមានសេចក្ដីសុខ។ ដូច្នេះហើយដោយមានការបង្រៀនពីលោកគ្រូ អ្នកគ្រូគួបផ្សំនឹងកិច្ចការស្រាវជ្រាវនេះទើបមានការយល់ដឹងកាន់តែច្បាស់ហេតុនេះសង្ឃឹមថាបងប្អូននិស្សិតនិងអ្នកសិក្សាទាំងឡាយយកចិត្តទុកដាក់ក្នុងកិច្ចការស្រាវជ្រាវរបស់ខ្លួនទោះជាមុខវិជ្ជាណាក៏ដោយទើបធ្វើឱ្យយើងមាននូវចំណេះដ៏ពិតប្រាកដបាននោះជាអ្វីដែលល្អពិត

# អនុសាសន៍

# អនុសាសន៍

ក្រោយបានសិក្សាស្រាវជ្រាវនិង ធ្វើការសន្និដ្ឋានរួចមកទាន់ទងនឹងប្រធានបទសុំកូនពេញលេញមួយនេះក្នុងនាមខ្ញុំជានិស្សិតផ្នែកនីតិសាស្រ្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ហើយជាប្រជាជនកម្ពុជាមួយរូបផងដែរ នាងខ្ញុំសូមផ្តល់នូវអនុសាសន៍ខ្លះៗ ចង់អោយប្រជាពលរដ្ឋទាំងអស់គ្នាចាំបាច់យល់ដឹងនឹងស្វែងយល់អោយបានច្រើនអំពីច្បាប់ នឹងត្រូវគោរពដាច់ខាតជាពិសេសយល់ដឹងផ្នែកនីតិវិធីនៃការសុំកូនដែលបានចែងនៅក្រមរដ្ឋប្បវេណី ជាពិសេសគឺច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ដែលមនុស្សគ្រប់រូបបានស្គាល់ នឹងឆ្លងកាត់ដែលធ្វើអោយមនុស្សមានការប្រែប្រួលជីវភាព អាចឈានដល់ការបែកបាក់គ្រួសារធ្វើអោយកុមារទទួលរងការខ្វះខាតសេចក្តី ឰ បែកបាក់គ្រួសារមានបញ្ហាសុខភាពរបស់ភាគីណាមួយដែលមិនអាចមានកូនបាន។

ហេតុនេះហើយយើងត្រូវពិចារណាអោយបានគ្រប់ជ្រុងជ្រោយមុនពេលសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ ចេះយោគយល់អាធ្យាស្រ័យគ្នាទៅវិញទៅមកដែលពិគ្រោះយោបល់គ្នា ជាកត្តាសំខាន់ធ្វើអោយគ្រួសារមានសេចក្តីសុខ កុមារជាច្រើនៗមានសុខសុភមង្គល ពិតប្រាកដប៉ុន្តែតែយ៉ាងណាមិញនៅក្នុងសង្គមខ្មែរយើងមានក្មេងកំព្រា ក្មេងអានាថាដែរដើរសុំទាននៅតាមផ្លូវសាធារណៈគ្មានជម្រក គ្មានអ្នកមើលថៃ អំពើរបស់ឪពុកម្តាយខ្លះគ្មានភាពទទួលខុសត្រូវ ភ្លើតភ្លើនបានបោះបង់កូនចោលតើអោយទៅពឹងអ្នកណា ? ដូច្នេះហើយទើបនាងខ្ញុំសម្រេចលើកយកប្រធានបទសុំកូនពេញលេញមកនិយាយការបង្កើតសុំកូនពេញលេញ គឺធ្វើឱ្យទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ដូចជាញាតិនៃឪពុកម្តាយបង្កើតផងដែរ ហើយអាចធ្វើឱ្យកុមារអភ័ព្វបានរួមរស់នៅជាមួយឪពុកម្តាយចិញ្ចឹមយ៉ាងមានសេចក្តីសុខហើយជួយអោយរាជរដ្ឋាភិបាល អ្នកច្បាប់ជួយបង្កើតច្បាប់ការពារ និងផ្តល់សិទ្ធដល់កុមារគ្រប់រូប។

# ឯកសារយោង

# ឯកសារយោង


លិខិតបទដ្ឋានគតិយុត្ត

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
2. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
3. ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០

ឯកសារ និង សៀវភៅផ្សេងៗ

- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសា ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨
- សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ ១-៣
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
- សៀវភៅ នីតិគ្រួសារ រៀបរៀងដោយ: អៀង សំណាង
- សៀវភៅបញ្ចប់សារណារបស់សិស្សច្បងដែលបន្សល់ទុកនៅបណ្ណាល័យ
- http://lovingkhmer.blogspot.com/ ( នីតិវិធីសុំកូនពេញលេញ )

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

**មាត្រា ១០០៦.–** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២

## សុំកូន

### កថាភាគទី ១

### សុំកូនពេញលេញ

**មាត្រា ១០០៧.–** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.–** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.–** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឳពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឳពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឳពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឳពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឳពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឳពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឳពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឳពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឳពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.–** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។

**មាត្រា ១០១៦.–** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.–** អានុភាពនៃការកាត់កាល់ស៊ុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយស៊ុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.–** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃស៊ុំកូនពេញលេញ

ប្រសិនបើបានបង្កើតស៊ុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីស៊ុំកូនឡើយ ។

**មាត្រា ១០១៩.–** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីស៊ុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២

## ស៊ុំកូនធម្មតា

**មាត្រា ១០២០.–** ពាក្យសុំនៃស៊ុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតស៊ុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៥ : គន្ថីទី ៧

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

# ផ្នែកទី ២ សុំកូន

## កថាភាគទី ១ សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីសុំកូនពេញលេញដែលកើតឡើងតាមសេចក្តីសម្រេចរបស់តុលាការ ក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹងដែលតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដោយខុសពីសុំកូនធម្មតាដែលជាសុំកូនតាមទម្រង់កិច្ចសន្យា និង កើតឡើងតាមការព្រមព្រៀងសុំកូន និង ការដាក់ពាក្យសុំចុះបញ្ជីសុំកូន ។ សុំកូនតាមទម្រង់កិច្ចសន្យា គឺជាករណីដែលភាគច្រើនទំនាក់ទំនងត្រូវបានចង ដោយពិចារណាទៅលើ "ស្ថានភាពរបស់មនុស្សពេញវ័យ" ប៉ុន្តែ ប្រព័ន្ធសុំកូនពេញលេញរបស់កម្ពុជា កំណត់យកអនីតិជនដែលមានស្ថានភាពគ្រួសារមិនអំណោយផលធ្វើជាកម្មវត្ថុ ដោយតម្រូវឱ្យមានការស្រាវជ្រាវ និង វិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ហើយសុំកូនប្រភេទនេះ មានគោលបំណងបង្កើតឡើងនូវទំនាក់ទំនងមួយដែលដូចគ្នាទៅនឹងទំនាក់ទំនងនៃឪពុកម្តាយ និង កូនបង្កើតដូច្នេះដែរ ។

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា សុំកូនពេញលេញមានសុពលភាព តែក្នុងករណីដែលមានការប្រកាសរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាលប៉ុណ្ណោះ ។ ដោយឡែកមាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏ទាមទារឱ្យមានការពិចារណាជាអតិបរមាលើឧត្តមប្រយោជន៍របស់កុមារ ដោយអាជ្ញាធរមានសមត្ថកិច្ចដែរ ។ សុំកូនពេញលេញ កើតឡើងតាមទម្រង់នៃការផ្តាច់ទំនាក់ទំនងចាស់ ដោយសាលក្រមរបស់សាលាដំបូង (tribunal de grande instance) ក្នុងករណីប្រទេសបារាំង ឬ តុលាការអាណាព្យាបាល (Vormundshaftsgericht) ក្នុងករណីប្រទេសអាល្លឺម៉ង់ ដោយដីកាសម្រេចរបស់តុលាការអនីតិជន ក្នុងករណីនៃប្រទេសអ៊ីតាលី និង ដោយដីកាសម្រេចរបស់តុលាការក្នុងករណីសហរដ្ឋអាមេរិក និង ប្រទេសអង់គ្លេស ។ មាត្រា ៨១៧-២ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា សុំកូនពិសេស (ពេញលេញ) ត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់តុលាការគ្រួសារ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប, មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៨១៧-២ នៃ

ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១-២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "សុំកូនគឺជាកិច្ចសន្យាមួយយ៉ាងឧឡារិកដែលចងបុគ្គលពីរ គឺម្នាក់ ហៅថា ឪពុកសុំ ហើយម្នាក់ទៀត ហៅថា កូនសុំ ឱ្យមានចំណងទាក់ទងគ្នាដូចជាបុត្តភាពមានខាន់ស្លាដែរ" ។

មាត្រា ១០៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ : "សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា" ។

## មាត្រា ១០០៨.- សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

(កំណត់)

សុំកូនពេញលេញគឺជាការផ្តល់នូវគ្រួសារដែលមានឪពុកម្តាយ និង មានលំនឹងគ្រប់គ្រាន់ ដល់កុមារដែលអភ័ព្វ ដូច្នេះ មាត្រានេះបានអនុម័តយកគោលការណ៍សុំកូនដោយសហការរវាងប្តីប្រពន្ធ ។ ក៏ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ពោលគឺករណីដែលអនាគតកូនចិញ្ចឹមត្រូវជាកូនចុងនោះ សុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្តីប្រពន្ធទេ ។

មាត្រា ៦ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ទុកលទ្ធភាពឱ្យច្បាប់របស់ប្រទេសនីមួយៗកំណត់ល័ក្ខខ័ណ្ឌថា ត្រូវទទួលស្គាល់សុំកូន តែចំពោះករណីដែលប្តី និង ប្រពន្ធសុំដោយសហការគ្នាប៉ុណ្ណោះ ឬ ទទួលស្គាល់សុំកូនដោយសហព័ទ្ធតែម្ខាង ដោយគ្រាន់តែទទួលការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត ។ តាមច្បាប់អង់គ្លេស ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (កថាខណ្ឌទី ៣ នៃមាត្រា ១៧៤១) កថាខណ្ឌទី ១ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណីបែលហ្ស៊ិក ក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក និង មាត្រា ៥៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់រុស្ស៊ី អ្នកនៅលីវក៏ត្រូវបានទទួលស្គាល់ថា មានលក្ខណសម្បត្តិជាឪពុក ឬ ម្តាយចិញ្ចឹមដែរ ។ ផ្ទុយទៅវិញ ច្បាប់អ៊ីតាលី និង មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន អនុម័តយកគោលការណ៍សុំកូនដោយការសហការរវាងប្តីប្រពន្ធ ។ ក្រៅពីនេះ ប្រទេសមួយចំនួនទៀតដែលកំណត់យកគោលការណ៍សុំកូនដោយសហការរវាងប្តី និង ប្រពន្ធ មានដូចជាប្រទេសស្វីស ដាណឺម៉ាក និង ស៊ុយអែត ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨ និង មាត្រា ៤៤ នៃច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់អ៊ីតាលី មាត្រា ៣២០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "ស្ត្រីគ្មានប្តីអាចសុំកូនគេចិញ្ចឹមបានដែរ" ។

## មាត្រា ១០០៩.- អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

(កំណត់)

អាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹមកំណត់ត្រឹម ២៥ ឆ្នាំ ហើយគម្លាតរវាងអាយុនៃឪពុកម្តាយចិញ្ចឹម និង អាយុរបស់កូនសុំ ដើម្បីឱ្យមើលទៅសមជាឪពុកម្តាយ និង កូន គឺ ២០ ឆ្នាំ ។

មាត្រានេះបានបញ្ញត្តនូវអាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹម និង គម្លាតអាយុសមរម្យរវាងឪពុកម្តាយ និង កូន ដោយបានសិក្សាអំពីទំនៀមទម្លាប់របស់កម្ពុជា ដោយសារមានការចាំបាច់តម្រូវឱ្យមានភាពចាស់ទុំទាំងផ្នែកស្មារតី និង រាងកាយ ដើម្បីបីបាច់ថែរក្សាដាក់ស្តែងនូវទារក ឬ កូនក្មេង ។

កិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់យកអាយុលើសពី ២១ ឆ្នាំ និង ក្រោម ៣៥ ឆ្នាំ ធ្វើជាបទដ្ឋាននីតិកម្មទាក់ទងនឹងអាយុអប្បបរមា ។ ប៉ុន្តែ នីតិកម្មនៃបណ្តាប្រទេសផ្សេងៗកំណត់យកខុសៗគ្នា ឧទាហរណ៍ដូចជាការកំណត់យកអាយុអប្បបរមា ១៨ ឆ្នាំ (ជាអាយុឈានដល់នីតិភាពដែលកំណត់ដោយរដ្ឋកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសរុស្ស៊ី និង ច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី) អាយុលើសពី ២១ ឆ្នាំ (ច្បាប់ស្តីពីសុំកូនក្នុងតំបន់រដ្ឋធានីសហព័ន្ធអូស្ត្រាលី) អាយុលើសពី ២៥ ឆ្នាំ (មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់អាយុលើសពី ២៥ ឆ្នាំ ប៉ុន្តែ ដោយយោងតាមទំនាក់ទំនងជាមួយនឹងគោលការណ៍សុំកូនដោយសហការរវាងប្តីប្រពន្ធផងនោះ បើសហព័ទ្ធម្ខាងមានអាយុលើសពី ២៥ ឆ្នាំ សហព័ទ្ធម្ខាងទៀតមានអាយុលើសពី ២០ ឆ្នាំ គឺជាការគ្រប់គ្រាន់ រីឯក្រមរដ្ឋប្បវេណីបារាំង តម្រូវឱ្យមានអាយុលើសពី ២៨ ឆ្នាំ ហើយត្រូវមានគម្លាតអាយុលើសពី ១៥ ឆ្នាំឡើងទៅ ។ ចំណែកឯក្រមរដ្ឋប្បវេណីបែលហ្ស៊ិកក៏ទាមទារឱ្យមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងហោចណាស់ ១៥ ឆ្នាំ ។ ក្រៅពីនេះ នៅមានមាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ច្បាប់ស្តីពីសុំកូនដាណឺម៉ាក ក្រមរដ្ឋប្បវេណីអេស្ប៉ាញ ជាអាទិ៍) ។ម្យ៉ាងទៀត ដោយហេតុថា គោលបំណងនៃសុំកូនពេញលេញ គឺការបីបាច់ថែទាំកុមារ ដូចគ្នាទៅនឹងឪពុកម្តាយ និង កូនបង្កើត ដូច្នេះ ទើបមានប្រទេសជាច្រើនទាមទារឱ្យមានគម្លាតអាយុប្រហែលចាប់ពី ១០ ទៅ ១៨ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៣-១-១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣៤៥ និង មាត្រា ៣៦៨ នៃក្រមរដ្ឋប្បវេណីបែលហ្ស៊ិក, មាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "បុរសត្រូវមានអាយុជាង ២៥ ឆ្នាំ. ត្រូវបងកូនសុំ ២០ ឆ្នាំ យ៉ាងតិច និង ត្រូវគ្មានកូនសោះ ទើបអាចសុំកូនគេចិញ្ចឹមបាន" ។

មាត្រា ១០៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា "ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស" ។

## **មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

(កំណត់)

ទាក់ទងនឹងចំនួនកូនសុំ យោងតាមទម្លាប់របស់កម្ពុជា សេចក្តីព្រាងដំបូងនៃក្រមនេះបានកំណត់ថា "(១) ឪពុកម្តាយចិញ្ចឹម អាចសុំកូនបាន ត្រឹម ២ (ពីរនាក់)" ប៉ុណ្ណោះ ។ សេចក្តីព្រាងនោះត្រូវបានរៀបចំឡើង ដោយមានមូលហេតុថា ដើម្បីឱ្យមានការបីបាច់ថែរក្សាកូនសុំឱ្យដូចជាកូនបង្កើត ចាំបាច់ត្រូវកម្រិតចំនួនកុមារដែលជាកូនសុំតាមសុំកូនពេញលេញ ។ ចំពោះសុំកូនអន្តរប្រទេស កូនសុំត្រូវបានកំណត់ត្រឹមមួយនាក់ប៉ុណ្ណោះ (អនុក្រឹត្យ លេខ ២៩ អនក្រ.បក ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាទៅចិញ្ចឹមជាកូននៅបរទេស ខែ មីនា ឆ្នាំ ២០០១) ។ម្យ៉ាងវិញទៀត តាមរយៈការបង្កើតសុំកូន ដើម្បីកសាងទំនាក់ទំនងដែលយកឪពុកម្តាយចិញ្ចឹមមកជាមេបាតែមួយគូ ដូចគ្នាជាមួយនឹងទំនាក់ទំនងជាមួយកូនបង្កើត កូនសុំនោះគួរមានអាយុក្រោមអាយុចូលរៀន ។ សុំកូនពេញលេញ គឺជាប្រព័ន្ធដែលផ្តល់ឪពុកម្តាយដល់កុមារតូចដែលត្រូវការបីបាច់ថែរក្សា ដូច្នេះ មាត្រានេះ ជាគោលការណ៍ កម្រិតតែចំពោះកុមារដែលមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំប៉ុណ្ណោះ ។

កថាខណ្ឌទី ១ មាត្រា ១២ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ហាមឃាត់ការកម្រិតដោយបញ្ញត្តិច្បាប់លើចំនួនកូនសុំដោយឪពុកម្តាយចិញ្ចឹមតែមួយ ហើយកថាខណ្ឌទី ២ នៃមាត្រាដដែលបញ្ញត្តថា "ជនដែលមានបំណងសុំកុមារធ្វើជាកូនសុំ មិនត្រូវហាមឃាត់សុំកូននោះដោយបញ្ញត្តិច្បាប់ ដោយសំអាងថា ជននោះមានកូនខាន់ស្លារួច ឬ កូនខាន់ស្លានឹងកើតមកនៅពេលខាងមុខឡើយ" មានន័យថា ហាមឃាត់ផងដែរចំពោះការដាក់ល័ក្ខខ័ណ្ឌលើលក្ខណសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹមថា ត្រូវតែគ្មានកូន ។ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏មិនមានកម្រិតចំនួនកូនសុំដែរ ។ មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា កម្រិតចំនួនកូនសុំត្រឹមម្នាក់ប៉ុណ្ណោះ ប៉ុន្តែ មាត្រា ១១០ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ បានកំណត់យកចំនួនត្រឹម ២ នាក់ ។

មាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា កូនសុំត្រូវជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ នៅលីវ ឬ មិនដែលរៀបអាពាហ៍ពិពាហ៍ ។ ចំពោះសុំកូនធម្មានុរូបកម្ម (ដែលក្លាយជាកូនមានខាន់ស្លា) នៅប្រទេសបារាំង ពីមុនកំណត់អាយុក្រោម ៥ ឆ្នាំ ប៉ុន្តែ បច្ចុប្បន្នគឺកំណត់អាយុក្រោម ១៥ ឆ្នាំ ។ ម្យ៉ាងទៀត ច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី ឆ្នាំ ១៩៨៣ កំណត់ថា កុមារដែលអាចក្លាយជាកម្មវត្ថុនៃសុំកូន ត្រូវតែជាអនីតិជន ប៉ុន្តែ

ពីមុន បានកំណត់យកអាយុក្រោម ៨ ឆ្នាំ ។ មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា ជាគោលការណ៍ កូនសុំត្រូវមានអាយុក្រោម ៦ ឆ្នាំ នៅពេលដាក់ពាក្យសុំស្មុំកូន ប៉ុន្តែ ក្នុងករណីដែលកុមារមានអាយុក្រោម ៨ ឆ្នាំ ហើយកុមារនោះបានទទួលការបីបាច់រក្សាពីឪពុកម្តាយចិញ្ចឹមតាំងពីមុនពេលគ្រប់អាយុ ៦ ឆ្នាំ នេះ ជាករណីលើកលែង ទោះបីជាកុមារមានអាយុ ៨ ឆ្នាំ ក៏មិនមានបញ្ហាអ្វីដែរ ។ ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសរបស់កម្ពុជា ដែលត្រូវបានតាក់តែងឡើងឆ្នាំ ២០០៩ កំណត់អាយុក្រោម ៨ ឆ្នាំ នៅពេលដាក់ពាក្យសុំស្មុំកូន (កថាខណ្ឌទី ២ នៃមាត្រា ៤) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "គេអាចសុំបានតែកូនមួយនាក់ប៉ុណ្ណោះ, ប្រសិនបើកូនដែលសុំមកនោះវា ស្លាប់ទៅ ហើយគ្មានកូនទៀតទេ គេអាចសុំកូនមួយនាក់ទៀតបាន" ។

មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំនោះត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

មាត្រា ១១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។ កូនចិញ្ចឹមត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

## **មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតស្មុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

(កំណត់)

ស្មុំកូនពេញលេញ គឺជាការផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និង មានគោលដៅយកកូនសុំនោះចូលទាំងស្រុងក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះ ចាំបាច់ត្រូវតែមានការយល់ព្រមពីឪពុកម្តាយបង្កើតដែលមានទំនាក់ទំនងផលប្រយោជន៍យ៉ាងជ្រាលជ្រៅជាមួយនឹងកុមារនោះ ។ ប៉ុន្តែ ក្នុងករណីដែលមានស្ថានភាពពិបាកនឹងទទួលការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ក្នុងករណីដែលការជំទាស់របស់ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំនោះ ការយល់ព្រមពីឪពុកម្តាយបង្កើត មិនចាំបាច់ឡើយ ។

កថាខណ្ឌទី ១ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីស្មុំកូនអឺរ៉ុប បញ្ញត្តថា ចំពោះកូនមានខាន់ស្លា ចាំបាច់ត្រូវមាន

ការយល់ព្រមពីឪពុកម្តាយ ហើយចំពោះកូនឥតខាន់ស្លា ចាំបាច់ត្រូវមានការយល់ព្រមពីម្តាយ ហើយក្នុងករណីដែលគ្មានឪពុកម្តាយ ចាំបាច់ត្រូវមានការយល់ព្រមពីជនដែលអនុវត្តអំណាចមេបាជំនួស ឬ អ្នកអាណាព្យាបាល ឬ ស្ថាប័នដែលអាចជំនួសអ្នកទាំងនេះបាន ។ កថាខណ្ឌទី ៣ នៃមាត្រានេះដែលចែងអនុញ្ញាតឱ្យមានការចែងក្នុងច្បាប់ថា មិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយចំពោះសុំកូនឡើយ ក្នុងករណីដែលឪពុកម្តាយត្រូវបានដកហូតអំណាចមេបា ឬ សិទ្ធិបីបាច់ថែរក្សាគ្រប់គ្រងកូន ។

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក៏ទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដែរ ( មាត្រា ១៧៤៨) ប៉ុន្តែ ក្នុងករណីដែលឪពុកម្តាយមិនអាចបង្ហាញឆន្ទៈបានជាបន្តឥតដាច់ ឬ ករណីដែលលំនៅឋានរបស់ឪពុកម្តាយមិនច្បាស់លាស់ មិនចាំបាច់មានការយល់ព្រមឡើយ ។ ក្រមរដ្ឋប្បវេណីបារាំងក៏បញ្ញត្តដែរថា ក្នុងករណីដែលសុខភាព និង ស្មារតីរបស់កុមារប្រឈមមុខនឹងគ្រោះថ្នាក់ ហើយឪពុកម្តាយមិនអើពើ ការមិនយល់ព្រមគឺជាការបំពានលើសិទ្ធិយល់ព្រម ដូច្នេះ ក៏មិនចាំបាច់តម្រូវឱ្យមានការយល់ព្រមដែរ ( មាត្រា ៣៤៧ និង មាត្រា ៣៤៨-២) ។ មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុនទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដើម្បីបង្កើតសុំកូន ហើយក៏ចែងលើកលែងនូវករណីដែលមិនចាំបាច់មានការយល់ព្រមដែរ ។

ម្យ៉ាងទៀត ប្រសិនបើកំណត់អាយុរបស់កូនដែលអាចត្រូវបានសុំបានខ្ពស់ ( ដោយវិសោធនកម្មនៃមាត្រា ១១០០) នៅប្រទេសបារាំង ចាំបាច់ត្រូវមានការយល់ព្រមពីក្មេងដែលមានអាយុលើសពី ១៣ ឆ្នាំ ( កថាខណ្ឌទី ៣ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង) រីឯរដ្ឋកាលីហ្វ័រញ៉ា តម្រូវឱ្យមានការយល់ព្រមពីក្មេងអាយុលើសពី ១២ ឆ្នាំ ( មាត្រា ៨៦០២ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ហើយប្រទេសកម្ពុជាក៏ដូចគ្នាដែរ ទាក់ទងនឹងទស្សនៈដែលការពារសិទ្ធិបញ្ចេញទស្សនៈរបស់ក្មេង ( មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) ចាំបាច់ត្រូវមានវិធានការផ្សេងៗនានា ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣២១ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុក និង ម្តាយមានខាន់ស្លា ឬ ឥតខាន់ស្លានៃកូនដែលឱ្យគេសុំនោះ ឬ បើគ្មានឪពុកម្តាយទេ, ជនជាអាណាព្យាបាលនៃកូននោះត្រូវឱ្យសេចក្តីព្រមព្រៀងរបស់ខ្លួនក្នុងកិច្ចសន្យាសុំកូននោះ" ។

មាត្រា ១១២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "ដើម្បីឱ្យការសុំកូនសំរេចទៅបាន ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។ បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់" ។

## មាត្រា ១០១២.- មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាង

ខ្វាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

( កំណត់ )

មាត្រានេះបញ្ញត្តអំពីមូលដ្ឋានសារធាតុដើម្បីវិនិច្ឆ័យក្នុងករណីដែលតុលាការបង្កើតសុំកូន ។ ប្រសិនបើតុលាការយល់ឃើញថា មិនសមរម្យឱ្យឪពុកម្តាយគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្តាយបាត់ខ្លួន ឬ មានវិបត្តិផ្នែករាងកាយដែលធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឬ ឪពុកម្តាយដែលធ្វើបាប ឬ បោះបង់កូនចោល ហើយយល់ឃើញថា ដើម្បីផលប្រយោជន៍កុមារ ចាំបាច់ត្រូវតែបញ្ចប់ញាតិភាពជាមួយឪពុកម្តាយនោះ ហើយបង្កើតសុំកូនជាមួយឪពុកម្តាយចិញ្ចឹម ទើបតុលាការអាចសម្រេចឱ្យបង្កើតសុំកូនបាន ។

មាត្រា ៨ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការប្រកាសសុំកូនបាន តែក្នុងករណីដែលបានជឿជាក់ថា សុំកូននោះនឹងធានាដល់ផលប្រយោជន៍របស់កុមារប៉ុណ្ណោះ ដោយសង្កត់ធ្ងន់ជាពិសេសថា តាមការប្រកាសសុំកូននេះ នឹងផ្តល់ឱ្យកុមារនូវគ្រួសារដែលមានស្ថិរភាព និង ភាពសុខដុមរមនា ។ មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏បញ្ញត្តដែរថា ប្រព័ន្ធសុំកូនត្រូវធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ។ កថាខណ្ឌទី ១ មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីបារាំង កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វីស ច្បាប់អង់គ្លេស និង កថាខណ្ឌ C មាត្រា ១៣ នៃក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក ក៏ទាមទារឱ្យសុំកូនឆ្លើយតបដោយជាក់លាក់ទៅនឹងសុខុមាលភាពកុមារ និង ឧត្តមប្រយោជន៍របស់កុមារដែរ ។

មាត្រានេះក៏យកលំនាំដូចគ្នាតាមមាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧ មាត្រា ៨ និង មាត្រា ២៥ នៃច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់អ៊ីតាលីដែលចែងថា អាចបង្កើតសុំកូនបានចំពោះកូនដែលត្រូវបានបោះបង់ ដែលមិនអាចទទួលបានការបីបាច់ថែរក្សាឱ្យបានសមរម្យពីឪពុកម្តាយ ឬ កុមារដែលត្រូវការពារជាចាំបាច់ ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយ

ជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

(កំណត់)

មាត្រានេះបានបញ្ញត្តអំពីអំឡុងពេលកំណត់មួយនៃការសាកល្បងចិញ្ចឹម ដើម្បីពិនិត្យមើលជាក់ស្តែងថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរ ឬទេ ហើយតើអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរ ឬទេ និងថា តើមានភាពចុះសម្រុងគ្នារវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមដែរ ឬយ៉ាងណា ។

មាត្រា ១៧ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ចែងថា អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យមើលស្ថានភាពគ្រប់គ្រងថែរក្សាកូនសុំដោយឪពុកម្តាយចិញ្ចឹមថា តើសុំកូនឆ្លើយតបនឹងផលប្រយោជន៍របស់កុមារដែរ ឬទេ ក្នុងអំឡុងពេលសមរម្យចាំបាច់ដើម្បីឱ្យអាចវាយតម្លៃបានគ្រប់គ្រាន់ ។ មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១២ នៃក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក ជាដើម បានកំណត់អំឡុងពេលជាគោលការណ៍ ចំនួន ៦ ខែ ប៉ុន្តែ ប្រទេសអ៊ីតាលីកំណត់ ១ ឆ្នាំ រីឯមាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វីស កំណត់ ២ ឆ្នាំ ហើយមាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ កំណត់អំឡុងពេលសមរម្យ ។ ក៏ប៉ុន្តែ ប្រសិនបើមានកំណត់ហេតុនៃស្ថានភាពគ្រប់គ្រងថែរក្សាកុមារតាំងពីដើមមក នៅក្នុងមណ្ឌលពិគ្រោះស្តីពីកុមារ ជាអាទិ៍ ហើយតុលាការអាចយកឯកសារទាំងនោះមកធ្វើជាធនធានសម្រាប់ការវិនិច្ឆ័យបាន នោះតុលាការអាចប្រើប្រាស់ឯកសារបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ១០១៤.-** ការបញ្ចប់ទំនាក់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

(កំណត់)

របបសុំកូនពេញលេញមានគោលបំណងចិញ្ចឹមកុមារដែលបានសុំ ឱ្យដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះ កូនសុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ។ បានសេចក្តីថា ការចូលជ្រៀតជ្រែក ឬ ការរំខានមិនសមស្របពីឪពុកម្តាយបង្កើត ដូចជា ការទាមទារយកកូនវិញ ឬ ការទាមទារចរចាជួបកូន

ជាដើម ត្រូវហាមឃាត់ ហើយអំពើតាមទំនើងដូចជាការទាមទារអាហារកាតព្វកិច្ចពីកូន នៅពេលដែលកូននោះពេញវ័យជាដើម ក៏ចាំបាច់ត្រូវដាក់ការរឹតត្បិតផងដែរ ។ ហេតុដូច្នេះ មាត្រានេះបានកំណត់ឱ្យបញ្ចប់ និង ផ្ដាច់ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ តាមរយៈការបង្កើតសុំកូនពេញលេញ ។

ក៏ប៉ុន្តែ ក្នុងករណីដែលសហព័ទ្ធម្ខាងសុំកូនដែលជាកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ដូចជាកូនសុំដែលជាកូនចុងការសុំកូនដោយសហព័ទ្ធតែម្ខាងជាការគ្រប់គ្រាន់ ហើយចំពោះការគ្រប់គ្រងថែរក្សាក្នុងនាមជាឪពុក ឬ ម្ដាយបង្កើតរបស់សហព័ទ្ធម្ខាងទៀត មិនចាំបាច់ឱ្យមានការបញ្ចប់ទំនាក់ទំនងញាតិភាពជាមួយនឹងឪពុក ឬ ម្ដាយបង្កើតនោះ និង ជាមួយញាតិលោហិតរបស់ឪពុក ឬ ម្ដាយបង្កើតនោះឡើយ ។

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប បានកំណត់ថា សុំកូនបង្កើតឱ្យមានទំនាក់ទំនងតតិយុត្តរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម ដូចគ្នានឹងទំនាក់ទំនងរវាងឪពុកម្ដាយ និង កូនមានខាន់ស្លាដែរ ហើយជាមួយគ្នានេះ ក៏រំលត់នូវទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើតផងដែរ ក៏ប៉ុន្តែនៅពេលដែលកូនសុំជាកូនមានខាន់ស្លា ឬ ឥតខាន់ស្លា ឬ កូនសុំរបស់សហព័ទ្ធម្ខាងទៀតរបស់ឪពុក ឬ ម្ដាយចិញ្ចឹមបញ្ញត្តិច្បាប់អាចកំណត់ទុកជាមុនថា សហព័ទ្ធម្ខាងទៀតនោះ ត្រូវប្រកាន់ខ្ជាប់នូវសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនដែលមានចំពោះកូនសុំ ។ រាល់បណ្ដាប្រទេសដែលអនុម័តយកសុំកូនពេញលេញ ឬ សុំកូនដោយផ្ដាច់ទំនាក់ទំនង តែងតែមានបញ្ញត្តិប្រភេទនេះជានិច្ច ‹ មាត្រា ៣៥៦ ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ២៦៧ នៃក្រមរដ្ឋប្បវេណីស្វីស ជាដើម› ។

‹ មាត្រាពាក់ព័ន្ធ›

មាត្រា ៨១៧-៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ១០១៥.- អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ

ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

( កំណត់ )

មាត្រានេះបញ្ញត្តថា កូនសុំត្រូវបានធ្វើឱ្យដូចជាកូនមានខាន់ស្លាទាំងស្រុង ក្នុងទំនាក់ទំនងរបស់កូនសុំជាមួយនឹងឪពុកម្ដាយចិញ្ចឹម ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើតដែរ ។ បានសេចក្ដីថា កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម (នាមត្រកូលរបស់ក្មេងនៅកម្ពុជា ជាទម្លាប់ គេអនុញ្ញាតឱ្យជ្រើសរើស) ហើយនៅពេលដែលកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ដូចជាកូនបង្កើតដែរ កូនសុំក៏មានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ សន្តតិកម្មពីឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ គឺជាប្រព័ន្ធដែលមានបំណងគ្រប់គ្រងថែរក្សាកូនសុំ ដោយកក់ក្ដៅ ដូចជាកូនបង្កើត នៅក្នុងគ្រួសាររបស់ឪពុកម្ដាយចិញ្ចឹម ដូច្នេះ ឋានៈរបស់កូនសុំនោះត្រូវបានធានាឱ្យដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ។

កថាខណ្ឌទី ១ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប បញ្ញត្តថា សុំកូនផ្ដល់ចំពោះឪពុកម្ដាយចិញ្ចឹមនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលឪពុកម្ដាយបង្កើតមានចំពោះកូនមានខាន់ស្លា ក្នុងទំនាក់ទំនងចំពោះកូនសុំ ហើយក៏ផ្ដល់ឱ្យកូនសុំនោះនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលកូនមានខាន់ស្លាមានចំពោះឪពុកម្ដាយបង្កើត ក្នុងទំនាក់ទំនងរបស់កូនសុំនោះចំពោះឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ ក្នុងបណ្ដាប្រទេសដូចជា ប្រទេសអ៊ីតាលី អាល្លឺម៉ង់ បារាំង សហរដ្ឋអាមេរិក ( មាត្រា ៨៦១៦ ដល់ មាត្រា ៨៦១៨ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា ) ប្រទេសអង់គ្លេស និង ស្វីស ជាដើម សុទ្ធតែមានបញ្ញត្តិបែបនេះ ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៨០៩ មាត្រា ៨១០ និង កថាខណ្ឌទី ២ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន. មាត្រា ៣៥៥ មាត្រា ៣៥៦ មាត្រា ៣៥៧ និង មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីបារាំង

មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "សុំកូននេះមានអានុភាពឱ្យកូននោះ ឆ្លងពីភាពជាកូននៃគ្រួសារមានខាន់ស្លា ឬ ឥតខាន់ស្លាមួយ ទៅជាកូននៃគ្រួសាររបស់អ្នកសុំវិញ" ។

មាត្រា ៣២៦ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំត្រូវយកនាមត្រកូលនៃឪពុកសុំ. កូនសុំត្រូវមានកាតព្វកិច្ច និង ករណីយកិច្ច ចំពោះឪពុកសុំ និង គ្រួសាររបស់ឪពុកសុំ ដូចជាកូនបង្កើតដែរ" ។

មាត្រា ៣២៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុកសុំត្រូវបីបាច់រក្សាកូនសុំ ដូចជាកូនខ្លួនបង្កើតដែរ" ។

មាត្រា ១១៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត" ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ

តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក- បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ- បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សុំកូនពេញលេញ មានបំណងផ្តល់នូវការគ្រប់គ្រងថែរក្សាដូចជាកូនបង្កើត ដូច្នេះ ជាគោលការណ៍ ការកាត់កាល់មិនត្រូវបានទទួលស្គាល់ឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបន្តទំនាក់ទំនងសុំកូនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារ ឬ ក៏ក្នុងករណីដែលអាចរំពឹងបាននូវការគ្រប់គ្រងថែរក្សាដោយគ្រប់គ្រាន់ដោយឪពុកម្តាយបង្កើត ជាករណីលើកលែង បញ្ញត្តិនេះទទួលស្គាល់ការរំលាយសុំកូនបាន ។

កថាខណ្ឌទី ១ មាត្រា ១៣ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា ក្នុងអំឡុងពេលដែលកូនសុំមិនទាន់ដល់នីតិភាព សុំកូនអាចត្រូវបានលុបចោលបាន តាមការសម្រេចរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាល តែក្នុងករណីដែលមានមូលហេតុធ្ងន់ធ្ងរប៉ុណ្ណោះ ។ បើមើលជាឧទាហរណ៍នៃបញ្ញត្តិច្បាប់របស់បណ្តាបស្ចឹមប្រទេសដែលមិនទទួលស្គាល់របបកាត់កាល់ មានដូចជាមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណីបារាំង និង ច្បាប់ប្រទេសអង់គ្លេស ស្វីស អ៊ីតាលី និង ស៊ុយអែត ជាដើម ។ ក៏ប៉ុន្តែ មាត្រា ១៧៦០ និង ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១៨ និង មាត្រា ១៩ នៃច្បាប់ស្តីពីសុំកូនដាណឺម៉ាក និង មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន ជាដើម បានទទួលស្គាល់ការកាត់កាល់ក្នុងករណីដែលមានស្ថានភាពជាក់លាក់មួយ (ដូចជាករណីដែលសមស្របទៅនឹងផលប្រយោជន៍របស់កុមារ ឬ ករណីដែលមានការបំពានករណីយកិច្ចរបស់ឪពុកម្តាយចិញ្ចឹម ដូចជាការវាយធ្វើបាបដោយហិង្សាដោយឪពុកម្តាយចិញ្ចឹម ជាដើម) ។ នៅរដ្ឋកាលីហ្វ័រញ៉ា ការលុបចោលដីកាសម្រេចបង្កើតសុំកូនពេញលេញ ដោយយកវិបត្តិក្នុងអភិវឌ្ឍន៍តាំងពីមុនពេលសុំកូន ឬ វិបត្តិផ្នែកស្មារតី ជាដើម មកជាមូលហេតុ ត្រូវបានទទួលស្គាល់ ក្នុងអំឡុងពេល ៥ ឆ្នាំ ហើយរបបលុបចោលនេះមានលក្ខណៈសារធាតុជាការកាត់កាល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦០ និង មាត្រា ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ១១៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "តុលាការប្រជាជន អាចបដិសេធកិច្ចសន្យា (សុំកូន) បាន តាមពាក្យប្តឹងសុំរបស់កូនចិញ្ចឹម របស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹមនោះ" ។

**មាត្រា ១០១៧.-** អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

(កំណត់)

មាត្រានេះអនុម័តយកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត និង ញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត ដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូន នៅពេលដែលសុំកូនពេញលេញត្រូវបានរំលាយដោយការកាត់កាល់ ។

នៅក្នុងនីតិកម្មដែលទទួលស្គាល់ការកាត់កាល់ នៅមានការខ្វែងគំនិតគ្នាលើចំណុចថា តើញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និង គ្រួសាររបស់ឪពុកម្តាយបង្កើតដែលបានបញ្ចប់ដោយការបង្កើតសុំកូន ត្រូវបានបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិ ឬ យ៉ាងណានោះ ។ ប្រទេសជប៉ុន អាល្លឺម៉ង់ អូស្ត្រាលី និង រុស្ស៊ី ជាដើម ប្រកាន់យកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិ ចំណែកឯប្រទេសដាណឺម៉ាកប្រកាន់យកជំហរផ្សេងៗខុសគ្នា អាស្រ័យទៅតាមអាយុរបស់កុមារ ឬ មូលហេតុនៃការកាត់កាល់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៦ និង មាត្រា ១៧៦៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ១០១៨.-** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ ។

(កំណត់)

ក្នុងករណីដែលសុំកូនពេញលេញគឺជាការសង្គ្រោះចំពោះកុមារអភ័ព្វ ការបង្ហាញនូវអង្គហេតុនៃសុំកូន អាចបំពានភាពឯកជន ហើយផ្តល់បច្ច័យអាក្រក់ដល់ការរីកចម្រើនល្អតលាស់ដ៏ល្អរបស់កុមារ ។ ម្យ៉ាងទៀត ការបង្ហាញដូច្នេះ

ក៏នាំឱ្យមានហានិភ័យ ដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្ដាយបង្កើត ដែលធ្វើឱ្យស្ថានភាពគ្រួសារកូនសុំ មានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវបរិស្ថានរីកចម្រើនល្អគួរសមដែលមានលំនឹងសម្រាប់កុមារ ។ ដូច្នេះហើយ មាត្រានេះបានកំណត់ថា បញ្ជីអត្រានុកូលដ្ឋាន និង សំបុត្រកំណើតថ្មី របស់សុំកូនដែលធ្វើឡើងដោយការបង្កើតសុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះរបស់ឪពុកម្ដាយបង្កើត ឬ ចំណុចស្ដីពីសុំកូនឡើយ ហើយត្រូវចុះថា ឪពុកម្ដាយចិញ្ចឹម គឺជាឪពុកម្ដាយបង្កើត ។

មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង បញ្ញត្តថា សាលក្រម ឬ សាលដីកាដែលប្រកាសបង្កើតសុំកូនពេញលេញ ត្រូវចុះនៅក្នុងបញ្ជីអត្រានុកូលដ្ឋាននៅកន្លែងកំណើតរបស់កូនសុំ ក្នុងអំឡុងពេល ១៥ ថ្ងៃ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ដោយសរសេរនូវថ្ងៃ និង ម៉ោងកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយចិញ្ចឹម ជាអាទិ៍ ដោយមិនចុះអ្វីទាក់ទងនឹងឪពុកម្ដាយបង្កើតឡើយ ហើយការចុះបញ្ជីនេះនឹងជំនួសឱ្យសំបុត្រកំណើតរបស់កូនសុំ ។ ក្នុងរដ្ឋកាលីហ្វ័រញ៉ា ក្នុងករណីសុំកូនពេញលេញ សំបុត្រកំណើតថ្មីដែលធ្វើឱ្យឪពុកម្ដាយចិញ្ចឹមដូចជាឪពុកម្ដាយបង្កើត ត្រូវបានចេញ ហើយសំបុត្រកំណើតចាស់ ត្រូវបានបញ្ចូលក្នុងស្រោមសំបុត្រ និង បិទជិត ហើយបោះត្រា (មាត្រា ៨៦១៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ, មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីសុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

(កំណត់)

មាត្រា ៩២០០ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា កំណត់ថា ការមើលឯកសារពាក់ព័ន្ធនឹងការសម្រេចស្ដីពីសុំកូន ដូចជាពាក្យសុំនៃសុំកូន លិខិតលះបង់អំណាចមេបា លិខិតយល់ព្រម របាយការណ៍ពីស្ថាប័នសម្របសម្រួលសុំកូន ជាដើម មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានស្ថានភាពជាពិសេស និង បញ្ជាក់មូលហេតុត្រឹមត្រូវ ។ ក៏ប៉ុន្តែ ប្រព័ន្ធបង្ហាញព័ត៌មានទាក់ទងនឹងកូនសុំ ត្រូវបានរៀបចំដែរ ដោយមានខ្លឹមសារថា ប្រសិនបើមានការយល់ព្រមពីឪពុកម្ដាយបង្កើតជាលាយល័ក្ខណ៍អក្សរ និង មានពាក្យសុំរបស់កូនសុំដែលមានអាយុលើសពី ២១ ឆ្នាំ ស្ថាប័នសម្របសម្រួលសុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់ឪពុកម្ដាយបង្កើតដល់កូនសុំបាន ហើយប្រសិនបើមានការ

យល់ព្រមពីកូនសុំដែលបានដល់នីតិភាព ស្ថាប័នសម្របសម្រួលសុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក ក៏អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់កូនសុំដល់ឪពុកម្ដាយបង្កើតបានដែរ (មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។ ក្រៅពីនេះ ក៏មានប្រព័ន្ធរៀបចំឱ្យមានការជួបមុខដោយផ្ទាល់រវាងកូនសុំដែលបានដល់នីតិជន និង ឪពុកម្ដាយបង្កើត ឬ បងប្អូនបង្កើត ផងដែរ ប្រសិនបើមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរ (មាត្រា ៩២០៤ និង មាត្រា ៩២០៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

យោងតាមការពិភាក្សា មាត្រានេះមិនកំណត់ឱ្យមានការយល់ព្រមពីឪពុកម្ដាយបង្កើតជាល័ក្ខខ័ណ្ឌឡើយ ហើយទទួលស្គាល់នូវសិទ្ធិទាមទារឱ្យបង្ហាញនូវសំណុំរឿងស្ដីពីសុំកូនដែលតុលាការរក្សាទុក ក្នុងករណីដែលមានភាពចាំបាច់ក្នុងការព្យាបាលជម្ងឺរបស់កូនសុំដែលបានដល់នីតិភាព ការរៀបអាពាហ៍ពិពាហ៍ ឬ គោលបំណងសមស្របផ្សេងទៀត ។ កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ទទួលស្គាល់សិទ្ធិដឹងអំពីប្រភពកំណើតរបស់ខ្លួនរបស់កុមារ ដូច្នេះ បញ្ហាប្រឈមនៅពេលខាងមុខ គឺការថ្លឹងថ្លែងរវាងសិទ្ធិរបស់ឪពុកម្ដាយបង្កើតដែលមិនចង់ឱ្យស្គាល់ ឬ ការទាមទារការរក្សាការសម្ងាត់ ជាមួយនឹងសិទ្ធិរបស់កុមារក្នុងការដឹងអំពីអត្តសញ្ញាណរបស់ខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា, កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ

## កថាភាគទី ២ សុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

(កំណត់)

មាត្រានេះមានគោលបំណងបង្កើតប្រព័ន្ធសុំកូនធម្មតា (សុំកូនសាមញ្ញ) នៅប្រទេសកម្ពុជា ជាទម្រង់ដែលសម្រួលសុំកូនពេញលេញដែលជារបបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់គ្រួសាររបស់ឪពុកម្ដាយចិញ្ចឹម ហើយកាត់ផ្ដាច់ទាំងស្រុងនូវទំនាក់ទំនងជាមួយគ្រួសារឪពុកម្ដាយបង្កើតនោះ ។ ប្រព័ន្ធសុំកូនធម្មតានេះត្រូវបានបង្កើតឡើង

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីកាតី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី) ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

## មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

## មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន ។

## មាត្រា ២៩.-ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

## មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្ដី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរបាន ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

## មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

## មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

## មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។

### មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

### មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច

ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់តាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

### មាត្រា ៣៩.- បណ្តឹងជំទាស់

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

### មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *
ត្រឹមត្រូវតាមច្បាប់ដើម



Kol

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍ និងគ្រួសារ

**មាត្រា ១០៥**~ តុលាការប្រជាជន ត្រូវបង្គាប់ឱ្យឪពុក ឬ ម្ដាយផ្ដល់អាហារកិច្ចឱ្យកូនជាដរាប តាមសមាមាត្រនៃធនធានរបស់ឪពុក ឬ ម្ដាយនោះ ។

អាហារកិច្ចនេះ ត្រូវផ្ដល់ឱ្យកូនតាមការកំណត់នៃសាលក្រម រហូតដល់កូននោះ មាននិតិភាព ។

ឪពុក ឬ ម្ដាយអាចត្រូវឱ្យរួចពីកាតព្វកិច្ចនេះបាន បើខ្លួនព្រមទទួលយកកូននោះទៅចិញ្ចឹមបីបាច់រក្សា ។

**មាត្រា ១០៦**~ សាលក្រមដែលកាត់សេចក្ដីឱ្យទទួលស្គាល់កូនឥតខាន់ស្លា អាចនឹងបង្ខំឱ្យឪពុកសងសោហ៊ុយសំរាលកូន និង ប្រាក់ចំណាយចិញ្ចឹមបីបាច់រក្សាកូនតាំងពីថ្ងៃដែលកូននោះកើតមក ទៅម្ដាយនៃកូននោះបាន ។

**មាត្រា ១០៧**~ កំណត់ដៃមួយច្បាប់នៃសាលក្រមស្ថាពរដែលកាត់សេចក្ដីឱ្យទទួលស្គាល់កូនឥតខាន់ស្លា ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើត ដើម្បីនិទ្ទេសអំពីបុត្តភាពនេះ នៅរឹមទំព័រនៃសំបុត្រកំណើត ។

## ផ្នែកទី ៤
## អំពីសុំកូន

**មាត្រា ១០៨**~ សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ហើយម្នាក់ទៀត ហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា ។

**មាត្រា ១០៩**~ ឪពុក ឬ ម្ដាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្ដាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស ។

**មាត្រា ១១០**~ គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។

-កូនចិញ្ចឹម ត្រូវមានអាយុតិចជាង ៨ ឆ្នាំ ។

**មាត្រា ១១១**~ សហព័ទ្ធណាមួយអាចនឹងសុំកូនយកមកចិញ្ចឹមបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។

ក្នុងករណីនេះ កូនចិញ្ចឹមត្រូវទុកជាកូនចិញ្ចឹមរបស់សហព័ទ្ធទាំងពីរនាក់ ។

**មាត្រា ១១២**~ ដើម្បីឱ្យការសុំកូនសំរេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្ដាយ ឬអ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។

បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់ ។